Free
សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

7 Video
ផ្ញើឥវ៉ាន់ទៅវិញទៅមកពីអាមេរិកនិងកម្ពុជា តាមយន្តហោះ២ថ្ងៃដល់
ផ្ញើ១ផោន តម្លៃ១០ដុល្លារ ធានាមិនបាត់ -ជើងផ្ញើដំណើរមានរាល់សប្តាហ៍
**ទទួលឥវ៉ាន់:** ថ្នាំពេទ្យ -ខោអាវ-ស្បែកជើង-ទូរស័ព្ទ-គ្រឿងបន្លាស់-គ្រឿងអលង្ការ
សូមទូរស័ព្ទមកលោក យុទ្ធ 978-876-1985 ដើម្បីឱ្យដឹងថ្ងៃផ្ញើ
660 Middlesex St. Lowell, MA 01851
978-710-6356

## OPPOSITION LEARNING TO LIVEWITH FEAR OF DEATH

by Zsombor Peter | March 16, 2017

Early this month, the opposition CNRP registered 11,572 candidates for June's commune elections-one for every seat-in what's likely to prove a bellwether for next year's all-important national election.

A few days later, Senate President Say Chhum, a stalwart of the long-ruling CPP, signed off on legislation giving his government sweeping new powers to do away with any party over vaguely worded offenses, left to its own discretion to interpret. Prime Minister Hun Sen, facing his toughest test in a quarter

Continued to Page 11

# រាត្រី“ក្រម៉ា”នៅលីនរដ្ឋម៉ាសាឈូសិត ដោយខ្មែរផុសស.រ.អា.



លោក ហុង ណេត និងភរិយា ថតជាមួយនឹងតំណាងខ្មែរផុសសហរដ្ឋអាមេរិក

**លីន:** រាត្រីជប់លាងរបស់សហគមន៍ខ្មែរ នៅ"លីន"មួយមានឧទ្ទិសនាមថា"ក្រម៉ា"បានត្រូវរៀបចំដោយសហគមន៍ខ្មែរដ៏ធំមួយ កាលពីថ្ងៃទី១៨មិនា នៅសាលអតីតយុទ្ធជនបារាំង-អាមេរិកាំង ដើម្បីរកកំរៃទៅរៀបចំពិធីចូលឆ្នាំ ខ្មែរមួយដែលនឹងត្រូវប្រារព្ធឡើងនៅឧទ្យានមុខសាលាក្រុងនៅថ្ងៃ២៩មេសាឆ្នាំ២០១៧ខាងមុខ។ កាសែតខ្មែរផុស ស.រ.អា.ក៏បានទៅចូលរួមជាកិត្តិយសដែរ។

ក្រម៉ាធ្លាប់ជាក្រណាត់សំពត់ដ៏មានប្រយោជន៍របស់ប្រជារាស្ត្រខ្មែរសម្រាប់ជាបន្លាស់ជាកន្សែងជាភួយសណ្តប់

តទៅទំព័រទី ១៤

# វិទ្យាល័យ“ឡូវែលហាយស្គូល”ត្រូវរៀបចំសារជាថ្មីតើពលរដ្ឋយល់យ៉ាងណា?

**ដោយខ្មែរផុសស.រ.អា.**




វិទ្យាល័យដ៏មានអាយុចំណាស់ពីឆ្នាំ១៩២២នៅឡូវែលបានត្រូវសាលាក្រុងនឹងក្រសួងអប់រំពិចារណារៀបចំសារជាថ្មីឡើងវិញ ឱ្យស្រប នឹងការវិវឌ្ឍន៏សង្គមអប់រំយុវជនសម័យជាងនឹងសម្របទៅនឹងបរិដ្ឋាននៃទីក្រុងឡូវែលផង។ កន្លែងដែលត្រូវសាងសង់វិទ្យាល័យនេះ មាន

តទៅទំព័រទី ២១

សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
Cambodian American Biweekly Newspaper
Connecting 10,000 Khmer-speaking households per Month with an average of 5 members per household. Free Newspaper copies are available in these cities:

Massachusetts:
- Lowell
- Lynn/Revere

Rhode Island:
- Providence
- Cranston

CELEBRATING 10 YEARS
Contact us for the Advertising Opportunity!
978-677-7163 | http:/khmerpost.us



# បានទទួលមួយ ឬទាំងពីរក្នុងចំណោមប័ណ្ណទាំងនេះ?

# ទទួលយកបន្ថែម។




ទទួលយកអត្ថប្រយោជន៍ច្រើនជាងអ្វីដែលអ្នកបច្ចុប្បន្នកំពុងទទួលបានពី Original Medicare និង MassHealth ជាមួយគម្រោង **UnitedHealthcare® Senior Care Options (HMO SNP)**។ វារួមបញ្ចូលគ្នានូវវេជ្ជបណ្ឌិតរបស់អ្នក មន្ទីពេទ្យ និងការគ្របដណ្តប់ឱសថមានវេជ្ជបញ្ជាគ្របទៅក្នុងគម្រោងមួយ គឺសម្រាប់ បុព្វលាភរ៉ាប់រងគម្រោង **$0**។**

## អត្ថប្រយោជន៍បន្ថែមអាចរួមមាន៖

**ឱសថមានវេជ្ជបញ្ជា**
រាប់ពាន់នៃឱសថអាចប្រើបាន។

**ការគ្របដណ្តប់លើទន្តសាស្ត្រ**
សហចំណាយ **$0** សម្រាប់ការដាក់ធ្មេញ និងក្រាសធ្មេញពាក់។

**ជំនួយលើមធ្យោបាយធ្វើដំណើរ**
សហចំណាយ **$0** សម្រាប់ការជិះទៅជួបវេជ្ជបណ្ឌិតតាមការណាត់។

**កាតាឡុកផលិតផលសុខភាព**
រហូតដល់ទៅ **$160** ក្នុងឥណទានប្រចាំឆ្នាំដើម្បីទិញ ផលិតផលសុខភាពពីកាតាឡុករបស់យើង។

**ទូរស័ព្ទមកថ្ងៃនេះដើម្បីចុះឈ្មោះ ឬទទួលបានចម្លើយទៅនឹងសំណួររបស់អ្នក។**



BOPHA PEOU
Licensed Sales Agent # 2016784
**Contact # (978) 221-9970, TTY 711**
[8 a.m. – 8 p.m. local time, 7 days a week]

**UHCCommunityPlan.com/MA**

**UnitedHealthcare®**
**Community Plan**

UnitedHealthcare SCO គឺជាគម្រោងថែទាំសុខភាពដែលមានការសម្របសម្រួលមួយ ដែលមានកិច្ចសន្យាជាមួយ Medicare និងជាប់កិច្ចសន្យាជាមួយកម្មវិធី Commonwealth of Massachusetts Medicaid ។ ការចុះឈ្មោះនៅក្នុងគម្រោងគឺផ្អែកទៅលើការបន្តកិច្ចសន្យាជាថ្មីរបស់គម្រោងជាមួយ Medicare ។ គម្រោងនេះគឺជាកម្មវិធីស្ម័គ្រចិត្ត ដែលអាចរកបានសម្រាប់អ្នកដែលមានវ័យចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ MassHealth Standard និង Original Medicare ។ ប្រសិនបើលោកអ្នកមាន MassHealth Standard ប៉ុន្តែលោកអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបាន Original Medicare លោកអ្នកនៅតែមានសិទ្ធិចុះឈ្មោះក្នុងគម្រោង MassHealth Senior Care Option និងទទួលបានអត្ថប្រយោជន៍ MassHealth ទាំងអស់របស់លោកអ្នកតាមរយៈកម្មវិធី SCO របស់យើង។ ព័ត៌មាននេះគឺមិនមែនជាការពិពណ៌នាពេញលេញអំពីអត្ថប្រយោជន៍នោះទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកគម្រោង។ ការកំណត់សហចំណាយ និងការដាក់កំហិតនានាអាចត្រូវអនុវត្ត។ អត្ថប្រយោជន៍ បុព្វលាភរ៉ាប់រង និង/ឬសហចំណាយ/សហធានារ៉ាប់រងអាចផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ បុព្វលាភរ៉ាប់រង សហចំណាយ សហធានារ៉ាប់រង និង ថ្លៃបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យ អាចប្រែប្រួលតាមកម្រិតនៃជំនួយបន្ថែមដែលលោកអ្នកទទួលបាន។ សូមទាក់ទងមកគម្រោងសម្រាប់ព័ត៌មានលំអិតបន្ថែមទៀត។ អ្នកចុះឈ្មោះមិនតម្រូវឲ្យបង់ប្រាក់ពីហោប៉ៅឡើយ។

H2226_150915_093829 Accepted
UHCSCO_150915_093829

CST10056_ H2226-001

# បុណ្យផ្កាប្រាក់“វត្តខ្មែរសាមគ្គីសន្តិការាម”នៅហាងសំពៅមាស

**ខ្មែរផុសស.រ.អា.**

**ឡូវែល:** ប្រជាពលរដ្ឋជាពុទ្ធសាសនិកប្រមាណ៤-៥០០នាក់បានមកចូលរួមបុណ្យផ្ការបស់វត្តសាមគ្គីរាមប្រារព្ធនៅភោជនីយដ្ឋាន "សំពៅមាស កាលពីថ្ងៃសៅរ៍ទី២៥ មិនា ឆ្នាំ២០១៧ ជាមួយព្រះសង្ឃ៥អង្គ ដែលមួយអង្គមកពី "រ៉ដអាយឡិន"នឹងមួយអង្គទៀតមកពីកម្ពុជារៀននៅសាកលវិទ្យាល័យ"ហាវើដ"។ ខកខានមិនបានធ្វើនៅវត្តដ៏ថ្មីស្រឡាងខ្លួនឯង នៅឯ"ធិងប៊ូរ៉ូ" ពីព្រោះវត្តនោះមិនទាន់ឆ្លងការត្រួតពិនិត្យរបស់ក្រុមបច្ចេកទេសក្រុងបានមិនអាចធ្វើពិធីបុណ្យនៅទីនោះបាននៅឡើយទេ។

វត្តសាមគ្គីសន្តិការាមបានសម្រេចកសាងវត្តថ្មីស្រឡាងមួយនៅលើសំណង់ចាស់ដែលមានទីធ្លាធំសមរម្យនៅធិងប៊ូរ៉ូចម្ងាយប្រមាណ១០នាទីបុណ្ណោះ ពី"វត្តត្រៃរតនារាម" ជាទីដែលព្រះសង្ឃវត្តក្រោមនឹងគណកម្មការបានសម្រេចចាកចេញពីទីដែលខ្លួនមានទំនាស់មិនចេះចប់នោះជិត៣០ឆ្នាំកាលពី៤-៥ឆ្នាំមុននេះ ប្រមូលថវិការដែលសៃសសល់យកមកទិញបានវត្តនឹងដីថ្មីនេះក្នុងតម្លៃ៣០ម៉ឺនដុល្លា ។

ក្រុមត្រួតពិនិត្យសមត្ថកិច្ចក្រុងបានទាមទារនាទីបញ្ចប់នៃការត្រួតពិនិត្យឱ្យវត្តសង់ថ្មីនេះដាក់បណ្តាញទឹកការពារភ្លើងឆេះ"ស្ព្រីងគ្លើ" នឹងបំពង់បញ្ចេញផ្សែងទៅក្រៅតាមគម្រូនៃ "ទីកន្លែងប្រើប្រាស់ជាសាធារណៈ"ដែលមានប្រើចង្ក្រានឧស្ម័ន, សំណង់បន្ថែមនេះនឹងត្រូវចំណាយប្រាក់ជាង១០ម៉ឺនដុល្លារថ្មីទៀត ដែលនេះជាបុព្វហេតុនៃពីធីបុណ្យផ្កាប្រាក់នៃថ្ងៃនេះ។ ប្រជាពលរដ្ឋជាពុទ្ធបរិស័ទ្ធមានសទ្ធាជ្រះថ្លាចូលបច្ច័យចាប់កុសលជាប្រាក់ជាង៣ម៉ឺនដុល្លាភ្លាម១ នាព្រឹកនោះ ក្នុងបរិយ៉ាកាសលះបង់ដើម្បីព្រះពុទ្ធសាសនាយ៉ាងរីករាយ ។







សំណង់វត្តថ្មីនេះ នៅពេលសង់ហើយសព្វគ្រប់នឹងចំណាយប្រាក់អស់ជាង៨០ម៉ឺនដុល្លា ដែលវត្តបានចេញប្រាក់ចំណាយរួចហើយចំនួន៥០ដុល្លានៅសល់៣០ម៉ឺនដុល្លាទៀត ដែលត្រូវរកមកចំណាយបន្ថែម។ ចំណាយទាំងនេះមិនបានរាប់បញ្ចូលនូវវិនិយោគក្នុងការទិញដីនឹងវត្តដំបូងទីបង្អស់ក្នុងតម្លៃ៣០ម៉ឺននោះនៅឡើយទេ ព្រះគ្រូចៅអធិការ **តទៅទំព័រទី ១៩**



វត្តខ្មែរសាមគ្គីសន្តិការាមទើបនឹងសង់ហើយថ្មី


## For your special day...

## សម្រាប់ថ្ងៃដ៏ពិសេសរបស់អ្នក



**The UMass Lowell Inn & Conference Center** provides timeless, modern elegance with a relaxing atmosphere.

You and up to 450 guests will be catered to by our attentive staff, while you celebrate in style and comfort.

We offer overnight lodging, scenic outdoor photo opportunities, and a variety of ceremony spaces, including smaller rooms for showers, rehearsal dinners, and engagement parties.

All of our menus can be personalized to suit your individual needs.

**សណ្ឋាគារ យូម៉ាសឡូវែលនឹងមណ្ឌលប្រជុំ**

ផ្តល់ជូនយ៉ាងទាន់ចិត្ត ជឿនលឿន សង្ហា ជាមួយនឹងបរិយាកាសយ៉ាងរំភើយ

លោកអ្នកនឹងភ្ញៀវរហូតដល់៤៥០នាក់អាចនឹងជប់លៀង ដោយមានការយកចិត្តទុកដាក់ពីបុគ្គលិកយើង នៅពេលដែលលោកអ្នកកំពុងរៀបពិធី ប្រកបដោយសម្បូរបែបនឹងយ៉ាងកក់ក្តៅ ។

យើងផ្តល់ជូនការស្នាក់អាស្រ័យឆ្លងរាត្រី, ទីធ្លាខាងក្រៅគួរឲ្យរំភើបសម្រាប់ មានឱកាសថតរូបនឹងបន្ទប់សម្រាប់ពិធីការគ្រប់ផុន,

រាប់ទាំង បន្ទប់តូច សម្រាប់បង្កក់កូន, ត្រៀមសម្រាប់ជប់លាងអាហារពេលល្ងាចនឹងពិធី ភ្ជាប់ពាក្យ...។
គ្រប់បញ្ជីមុខម្ហូបអាចនឹងរៀបចំជូនស្របតាមតម្រូវការរបស់បុគ្គលម្នាក់ៗបាន ។

UMASS LOWELL
Inn & Conference Center

**UMass Lowell Inn & Conference Center**
50 Warren St., Lowell MA 01852 978-934-6920 877-886-5422 **www.uml.edu/icc**

# សមាគមអង្គរប្រារព្ធខួបអាយុ៣០ឆ្នាំនៅឡូវែល


ពិន សំខុន

**ដោយ ពិន សំខុន**

ថ្នាក់ដឹកនាំនឹងសមាជិកសមាគមអង្គរនៅឡូវែល សហរដ្ឋអាមេរិកបានបង្ហាញការព្យាយាមយ៉ាងស្វិតស្វាញរបស់ខ្លួន ក្នុងការថែរក្សាមរតកសិល្បៈជាវប្បធម៌ខ្មែរ នៅក្រៅប្រទេសរហូតដល់មានអាយុបាន៣០ឆ្នាំ។ គឺជាសមាគមវប្បធម៌ខ្មែរដ៏មានអាយុចំណាស់ឆ្នាំបំផុត ហើយពង្រីកបានជាក្រុមរបាំខ្មែរដ៏ធំបង្អស់មួយនៅឆ្នេរខាងកើតនៃសហរដ្ឋអាមេរិក។ បង្កើតឡើងដោយអ្នកស្រឡាញ់វប្បធម៌ខ្មែរ២រូប កាលពីឆ្នាំ១៩៨៦


សមាគមអង្គរទទួលប័ណ្ណកោតសរសើរ

រូបថតដោយ Master Phousita Huy Awarded

គឺលោក ធីម ធូ នឹងលោក សាណារា ជា ដែលជាស្ថាបនិកដំបូងបង្អស់នៃសមាគមអង្គរធ្វើការដោយស្ម័គ្រចិត្ត រំលែកពេលពីការងារចិញ្ចឹមជីវិតផង នឹងបន្ថែមពេលការងារបំរើសិល្បៈផង។

កិច្ចប្រឹងប្រែងយ៉ាងព្យាយាមជាមួយនឹងអ្នកគ្រូលោកគ្រូបង្ហាត់ទាំងអស់សមាគមអង្គរ ទើបនឹងទទួលប័ណ្ណកោតសសើរដ៏ខ្ពង់ខ្ពស់មួយ កាលពីសប្តាហ៏មុននេះ ពីអ្នកគ្រប់គ្រង "ឧទ្យានប្រវត្តិសាស្ត្រជាតិ" ដែលតែងតែជួយជាការលើកទឹកចិត្តនឹងផ្តល់ទីស្នាក់ការសម្រាប់ហាត់រៀនរបាំដល់សិស្សតាំងតែពីច្រើនឆ្នាំមកហើយ។

មកទល់ពេលនេះ កុមារាកុមារីខ្មែរនៅឡូវែលរាប់ពាន់នាក់ហើយ ដែលបានចូលមកហាត់ហ្វឹកហ្វឺនយ៉ាងគ្មានទៀយហត់នឹងយ៉ាងទៀងទាត់ រហូតដល់បានសម្រេចជាសិល្បៈករជានាថករ នឹងខ្លះបានក្លាយជាគ្រូជំនួយរបស់សមាគមអង្គរទៀតផង ពីព្រោះតែមានការចូលចិត្តពីសិស្សខ្លួនឯងផង នឹងការចូលចិត្តពីឪពុកម្តាយផង, ថែមពិលើនេះ សមាគមមានការថែររក្សាវិន័យនឹងសិលធមិនាពេលបង្ហាត់ដ៏ខ្ពស់ដល់សិស្សដែលមជ្ឈមណ្ឌលហាត់ហ្វឹកហ្វឺនបានក្លាយជាទីអប់រំមួយដ៏ប្រសើរផង។

លោក ធីម ធូ បាននិយាយកាលពីថ្ងៃអាទិត្យ ទី២៦ មិនា នេះថា សមាគមមានប្រាក់ចំណូលនឹងជំនួយប្រមានជា១២ម៉ឺនដុល្លាក្នុងមួយឆ្នាំ ហើយឆ្នាំខ្លះឡើងដល់ជាង២០ម៉ឺនផងក៏មានតែមិនច្រើនដងទេ សម្រាប់គ្រប់គ្រងដែលចែកជា អំណោយជំនួយការសម្តែងឆាកសិល្បៈ, រីឯកន្លែងហាត់របស់យើងខាង "ឧទ្យានប្រវត្តិសាស្ត្រជាតិ" គេគ្រាន់តែសុំឱ្យយើងសម្តែងឱ្យគេ៦ដងក្នុងមួយឆ្នាំ ទៅតាមកន្លែងដែលគេចង់ឱ្យមានរបាំខ្មែរ យកទៅផ្សព្វផ្សាយតែបើសិនជាគិតចំណាយដែលត្រូវបង់រាល់ខែនោះទៅវិញ យើងត្រូវមានថវិការយ៉ាងហោចណាស់ក៏២ម៉ឺងក្នុង១ឆ្នាំៗដែរ។ ឥឡូវនេះយើងមានគ្រូបង្ហាត់គ្រប់គ្រាន់សម្រាប់បង្ហាត់សិស្ស៥០-៦០នាក់ រីឯសិស្សចាស់

**តទៅទំព័រទី ១៩**



# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

**AccuCare**
**Home Care Agency**
**Group Adults Foster Care Program**

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។



**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- រស់នៅផ្ទះរដ្ឋ

អាយុ ២២ ឆ្នាំឡើងទៅ

- មាសហ៊ែលស្តង់ដា

**ផលប្រយោជន៏ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# តំណាងរាស្ត្រ ហូ វ៉ាន់ ឆ្លើយតបនឹងការចោទ សង្គ្រោះជាតិថា “មិនស្របច្បាប់”

**ដោយខ្មែរផុសស.រ.អា.**

លោក ហូ វ៉ាន់ តំណាងរាស្ត្រពអាណត្តិរបស់គណបក្សសង្គ្រោះជាតិបានថ្លែងបញ្ជាក់ពីស្ថានការនយោបាយបច្ចុប្បន្ននៅកម្ពុជា កាលពីថ្ងៃទី២៥មិនា នៅពេលដែលលោកកំពុងធ្វើទស្សនកិច្ចនៅទីក្រុងឡូវែលនៅចំពោះមុខសមាជិសមាជិកាបក្សរបស់លោកប្រមាណ២០នាក់ ដែលថា "ប្រធាននឹងអនុប្រធានថ្មីនៃគណបក្សសង្គ្រោះជាតិមានភាពមិនស្របច្បាប់"នោះលោកផ្តល់ការបំភ្លឺយ៉ាងនេះថា:



លោក ហូ វ៉ាន់ កំពុងពន្យល់សមាជិកសង្គ្រោះជាតិនៅឡូវែល

-គណបក្សសង្គ្រោះជាតិបានធ្វើសមាជរបស់ខ្លួនយ៉ាងប្រញាប់ប្រញាល់ កាលពីថ្ងៃទី០២មិនា។ យើងមានពេលតែពាខែប៉ុណ្ណោះដើម្បីសម្របទៅតាមច្បាប់ថ្មីដែលទើបនឹងចូលជាធរមានដែលតម្រូវឱ្យគណបក្សសង្គ្រោះជាតិតែងតាំងប្រធានថ្មីបន្ទាប់ពីលោកសមរង្ស៊ីបានលាលែងពីដំណែងភ្លាម១ ដើម្បីកុំឱ្យរងអំណាចនៃច្បាប់ថ្មីនោះ ។

-ក្នុងសមាជនោះ យើងបានកែប្រែមាត្រា៤៧-៤៨នៃលក្ខន្តិកៈសង្គ្រោះជាតិបន្ទាប់មកយើងជ្រើសរើសប្រធានថ្មីនឹងអនុប្រធានពរូបស្របតាមមាត្រាថ្មីរបស់យើងនោះ ។

-លិខិតនៃ"មាត្រាកែប្រែថ្មីនឹងសមាសភាពនៃប្រធាននឹងអនុប្រធានថ្មី"ក៏បានបញ្ជូននាថ្ងៃបន្ទាប់ទៅកាន់ក្រសួងមហាផ្ទៃដែលបានទទួលយល់ព្រមថា ស្របច្បាប់អនុញ្ញាត្តិឱ្យប្រធានមានការចុះឈ្មោះបេក្ខជនឃុំសង្កាត់របស់យើង ហើយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏មានសរសេរសំបុត្រជូនពរប្រធាននឹងអនុប្រធានគណបកសថ្មីថែមទៀត ។

-អ្វីដែលជារឿងថ្មីកើតឡើង គឺក្រសួងមហាផ្ទៃបានយកលក្ខន្តិកៈចាស់យកមកផ្ទៀងផ្ទាត់នឹងសេចក្តីសម្រេចថ្មីរបស់សមាជបក្សដែលជាហេតុធ្វើឱ្យមានការភ័ន្តច្រឡំថា ការតែងតាំងថ្មីនេះជាការខុសច្បាប់, ការពិតត្រូវពិនិត្យមើលលិខិតនៃការកែរប្រែលក្ខន្តិកៈថ្មី ត្រង់មាត្រា៤៧-៤៨ ដែលផ្ទាប់ជាមួយការតែងតាំងនោះ ទើបបានស្របច្បាប់ ។

-ភាពមិនស្របច្បាប់នេះ បើពិតជាមានមែនអាចនឹងមានភាពធ្ងន់ធ្ងរពីព្រោះបើប្រធានមិនស្របច្បាប់ទៅហើយ អ្នកតំណាងរាស្ត្រក៏មិនស្របច្បាប់ដែរ ដាក់បេក្ខភាពមេឃុំចៅសង្កាត់ក៏មិនស្របច្បាប់ទៀត... ក៏ប៉ុន្តែនេះគ្រាន់តែជារឿង"បច្ចេកទេស"តែប៉ុណ្ណោះ ដែលក្រសួងមហាផ្ទៃមានភារកិច្ចប្រាប់មកយើង ដើម្បីធ្វើការកែតម្រូវនូវអ្វីដែលធ្វើមិនទាន់គ្រប់គ្រាន់ជាការស្រេច...

បើមើលបទពិសោធន៍នៅសហរដ្ឋអាមេរិក ឬនៅប្រទេសបារាំង ដែលជាប្រទេសសេរី បើមានករណីរបៀបនេះ ក្រសួងមានសមត្ថកិច្ច គេប្រាប់នឹងទាមទារឱ្យបំពេញសំណុំបែបបទឱ្យបានស្របច្បាប់មិនរំលាយគណបក្សចោលទេ...ក៏ប៉ុន្តែនៅកម្ពុជាគណបក្សកាន់អំណាចដែលកាន់ក្រសួងមហាផ្ទៃ, មានបំណងរំលាយគណបក្សប្រឆាំងរបស់ខ្លួន ជាពិសេសនៅពេលដឹងថា គណបក្សប្រឆាំងនោះ មានប្រជាប្រិយភាពជាងគណបក្សខ្លួន, ករណីបច្ចេកទេសក៏អាចក្លាយជាករណីនយោបាយបានដែរ ៕


## ដំណើងលក់ហាងធ្វើក្រចកចំនួន២កន្លែង

១. LYNN មានទីតាំងទើបនឹងសាងសង់ថ្មី, តំលៃជួល$1600ក្នុង១ខែ បូកបញ្ចូលទាំងកំដៅ ។ មានកៅអីសម្រាប់ធ្វើជើង៤ និងតុសម្រាប់ធ្វើដៃ៤ ។ លក់ក្នុងតំលៃ $50,000 ។ មានទីតាំងនៅចំកណ្តាល, ចរាចរណ៍ធ្វើដំណើរច្រើន និងកន្លែងចតរថយន្តខ្លួនឯង ។

២. PEA BODY មានទីតាំងល្អស្អាត ដែលបានបើកដំណើរការបាន៩ឆ្នាំហើយ ។ មានកៅអីសម្រាប់ធ្វើជើង 6, តុសម្រាប់ធ្វើដៃ 9, បន្ទប់បករោម 1, បន្ទប់ម៉ាស់សាខ្លួន 1, និងបន្ទប់ម៉ាស់សាមុខ 1. នៅជិត North Shore Mall, ទីតាំងល្អបំផុត, រកចំណូលបានខ្ពស់, មានកន្លែងចំណតរថយន្តធំទូលាយ, មានចរាចរណ៍ធ្វើដំណើរច្រើន និងមានអ្នកធ្វើក្រចកចំនួន ៨-៩ នាក់កំពុងធ្វើការងារ ។

តំលៃលក់ **$200,000** ។

សូមទំនាក់ទំនង Dianna តាមរយៈអ៊ីម៉ែល dianna10895@gmail.com, ផ្ញើរសារឬទូរស័ព្ទលេខ **617-429-1621**



ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៏
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**
www.thomasinlowell.com



## កាសែតដែលបំរើសហគមន៏ខ្មែរមានអ្នកអានច្រើនជាងគេបង្អស់ នៅឆ្នេរខាងកើតសហរដ្ឋអាមេរិកតាំង១០ឆ្នាំមកហើយ

**KhmerPost USA, LLC**
សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក

អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us

ផ្សាយពាណិជ្ជកម្ម **Advertising**
អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ **Editorials**
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us
ការីនិពន្ធ Staff Writers:
អ្នកនិពន្ធកិត្តិយស **Contributing Writers:**
Richard Howe Jr,
ច្នៃសោភ័ណភាពកាសែត **Design Artist**
Heng Chhunleng
ជំនួយការរដ្ឋបាល Office Coordnator
Sochet Chhen

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

Follow us: Facebook | Twitter @KhmerpostUSA

# FIND YOUR PARK with Free Family Fun – National Park Week at Lowell National Historical Park

មានអ្វីខ្លះដែលក្រុមគ្រួសារលោកអ្នកអាច ទៅកំសាន្តបានដោយមិនបង់ថ្លៃ ?

នៅ"ឧទ្យានប្រវត្តិសាស្រ្តជាតិ"នាសប្តាហ៍ខាងមុខ

**Lowell, Massachusetts.** — In town for April break? Make Lowell's April PLAYcation your destination for free family fun in our community! April PLAYcation is an annual festival of family activities that gets kids involved in the life of their city during April school vacation, April 15-23, 2017. Events are hosted by Lowell National Historical Park and several partner organizations and take place at locations throughout Lowell. All programs are free, but many require pre-registration – plan ahead and register early! The complete schedule of events will be available starting April 1 at www.lowellkidsweek.org.

PLAYcation offers over twenty free programs and builds connections among a diverse group of local organizations, agencies, and businesses in the city. Kids and families will enjoy an exciting variety of new programs, as well as many returning favorites. There's something for everyone, from toddlers to teenagers.

April PLAYcation also coincides with National Park Week, an annual celebration of "America's best idea"in more than 400 national park sites across the country. In addition to the PLAYcation programs, check out all the free family fun happening in Lowell during National Park Week:

· Your City Saturday: Saturday, April 15th. Lowell National Historical Park is kicking off April School PLAYCation week with a free, fun day exploring the Boott Cotton Mills Museum and the Tsongas Industrial History Center. Stop by the Center on the 3rd floor of the Boott Cotton Mills Museum (110 John Street) anytime from 1 p.m. to 4 p.m. This month's Your City Saturday offers an afternoon of hands-on history! Think like an engineer in the design, build, and test challenge. Time travel and handle objects immigrants brought with them to Lowell. Card, spin, and weave, and learn how cloth is made.






Fee-free days at Boott Cotton Mills Museum: On April 15th, 16th, 22nd and 23rd (the weekends on either end of National Park Week), bring the family for a free visit to the museum and experience the sights and sounds of an operational 1920s era weaveroom, and the stories of Lowell's mills and workers. The Boott Cotton Mills Museum is open daily from 9:30 a.m. to 5 p.m.






Junior Ranger Day: Saturday, April 15th. Explore, Learn, Protect! Kids can take part in a museum scavenger hunt, earn a badge and certificate, and become a Lowell National Historical Park junior ranger. All day at the Boott Cotton Mills Museum (and through PLAYcation week, while supplies last).

Celebrate Earth Day: PLAYcation includes arts workshops focused on crafts and activities to prepare for the Lowell Earth Day celebration on Sunday, April 23. The celebration is sponsored by UMass Lowell and presented by the university and community partners. The celebration kicks off with a parade from the Lowell National Historical Park Visitor Center at 12 noon on Sunday, April 23. The parade will finish at UTEC Lowell (35 Warren Street) where the Earth Day Festival will take place from 12 noon to 3:30 p.m. For more on Lowell's Earth Day, visit http://www.lowellearthday .org/.

Free parking is available at the Visitor Center lot at 304 Dutton Street. The Boott Cotton Mills Museum is a 10-15 minute walk from the Visitor Center lot. Paid parking is available one block from the museum with on-street metered parking, or the city parking garage at John and French Streets.

For more information on PLAYcation events and activities, visit www.lowellkidsweek.org/. To learn more about park offerings, the Junior Ranger program, the Boott Cotton Mills Museum, the Mill Girls and Immigrants Exhibit, ranger-led tours, and upcoming special events stop by the Visitor Center at 246 Market Street, contact Lowell National Historical Park at (978) 970-5000, or visit www.nps.gov/lowe .

Submitted by Philip S. Lupsiewicz, NPS



# កម្ពុជាបដិសេធការស្នើរសុំនាំចេញផលិតផលទឹកដោះស្ត្រីមកកាន់អាមេរិក

ប្រទេសកម្ពុជាបានធ្វើការផ្អាកជាបណ្ដោះអាសន្នមិនឱ្យក្រុមហ៊ុនអាមេរិកមួយដែលមានមូលដ្ឋាននៅក្នុងរដ្ឋយូតាឈ្មោះ អ៊ែមប្រូសៀ ឡាបស៍ (Ambrosia Labs) ធ្វើការនាំចេញនូវផលិតផលទឹកដោះស្ត្រីដោយសារក្រុមហ៊ុននេះដំណើរការពុំទាន់មានច្បាប់អនុញ្ញាតនៅឡើយ ។



ការិយាល័យតំណាងឲ្យក្រុមហ៊ុន អ៊ែមប្រូសៀ ឡាបស៍ នៅក្រុងភ្នំពេញ (រូបថតដោយ AFP)

យោងតាមសេចក្ដីរាយការណ៍របស់ទីភ្នាក់ងារសារព័ត៌មានបារាំង AFP កាលពីថ្ងៃទី ២០ ខែមីនាក្រុមហ៊ុន អ៊ែមប្រូសៀ ឡាបស៍ បានអះអាងខ្លួនឯងថា ជាក្រុមហ៊ុនដំបូងគេបង្អស់ដែលនាំចេញផលិតផលទឹកដោះគោប្រភេទនេះពីក្រៅប្រទេស ដើម្បីដាក់លក់ ក្នុងសហរដ្ឋអាមេរិក សម្រាប់មាតាដែលមិន អាចផលិតទឹកដោះខ្លួនឯងបានគ្រប់គ្រាន់ ឬចង់បំបៅកូនដោយទឹកដោះធម្មជាតិ ។


ទឹកដោះស្ត្រីដែលបរិច្ចាកនៅក្រុងឱនវ ក្នុងរដ្ឋខូឡារ៉ាដូ

ក្រុមហ៊ុននេះ បានដំណើរការក្នុងប្រទេសកម្ពុជាដោយធ្វើការប្រមូលទិញទឹកដោះពីស្ត្រីក្រីក្រដែលមានជីវភាពខ្វះខាតសម្រាប់ធ្វើការនាំចេញ។ ប្រភពដដែរ បានបន្តថាផលិតផលទឹកដោះនេះ ត្រូវបានប្រមូលទិញរួចបង្កក និងដឹកជញ្ជូនមកកាន់សហរដ្ឋអាមេរិកដោយដាក់លក់ក្នុងតំលៃ២០ដុល្លារអាមេរិកក្នុងមួយកញ្ចប់ដែលមានចំណុះ 50 ox (147 ml) ។

ដោយសារពុំទាន់មានច្បាប់អនុញ្ញាតអគ្គនាយកដ្ឋានគយ និងរដ្ឋាកររបស់កម្ពុជាបានផ្អាកការនាំចេញផលិតផលទឹកដោះរបស់ក្រុមហ៊ុនអាមេរិកនេះជាបណ្ដោះអាសន្នសិន។ អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានប្រាប់AFPឱ្យដឹងថា ដោយសារផលិតផលទឹកដោះនេះមានប្រភពមកពីសេរីរាង្គរបស់មនុស្ស ដូច្នេះក្រុមហ៊ុនត្រូវទំនាក់ទំនងទៅក្រសួងសុខាភិបាលដើម្បីសុំច្បាប់អនុញ្ញាតជាមុន ។

បន្ទាប់ពីមានការចុះផ្សាយទាក់ទងនឹងការផ្អាកការនាំចេញនោះដោយអាជ្ញាធរខ្មែរនេះមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF) ប្រចាំកម្ពុជាក៏បានប្រាប់AFPកាលពីថ្ងៃទី២២ ខែមីនា ថា ខ្លួនថ្កោលទោសយ៉ាងខ្លាំងដល់ក្រុមហ៊ុនអាមេរិក អ៊ែមប្រូសៀ ឡាបស៍ ចំពោះការលក់ទឹកដោះធម្មជាតិពីស្ត្រីកម្ពុជាដែលក្រីក្រ និងងាយរងគ្រោះទៅកាន់សហរដ្ឋអាមេរិក ដោយចាត់ទុកទង្វើរនេះជាការកេងប្រវ័ញ្ចលើស្ត្រីខ្មែរ និងច្បាប់ត្រូវតែហាមឃាត់ ហើយទឹកដោះប្រភេទនេះ គួរតែរក្សាទុកប្រើប្រាស់ក្នុងស្រុកដោយសារកុមារក្នុងប្រទេសកម្ពុជានូវប្រឈមនឹងកង្វះអាហាររូបត្ថម្ភនៅឡើយ ។

ជាលទ្ធផល កាលពីថ្ងៃទី ២៨ ខែមិនា រដ្ឋាភិបាលបានធ្វើការសម្រេចបរិសេធការស្នើរសុំនាំចេញរបស់ក្រុមហ៊ុន គុណមាតា ដែលមានក្នុងបញ្ជីពាណិជ្ជកម្ម អ៊ែមប្រសៀ ឡាបស៍ និងទប់ស្កាត់រាល់ការប្រមូលទិញ និងនាំចេញទឹកដោះស្ត្រីពីកម្ពុជាដោយលើកហេតុផលថា ប្រទេសកម្ពុជាក្រលំបាក់យ៉ាងណាក៏មិនដល់កិរិតទឹកដោះម្ដាយនោះដែរ ៕

**ប្រែសម្រួលដោយ សុខារ័ត្ន កូយ**

THE SPIEGEL CENTER
ADVANCED FACIAL AESTHETICS



ជឿទុកចិត្តលើមុខរបស់អ្នក
អ្នកជំនាញមួយ!

យើងមានបទពិសោធន៍ និងជំនាញក្នុងការងារតែមួយគត់
គឺ Rhinoplasty ការវះកាត់ត្របកភ្នែកពីរជាន់
ដកចេញស្លាកស្នាមលើផ្ទៃមុខ និងធ្វើឲ្យបបូរមាត់ស្រស់ស្អាត។
ជាអ្នកត្រួសត្រាយក្នុងថ្នាំ Botox និងធ្វើស្បែកឲ្យល្អឡើងវិញ។
សម្រាប់ការព្យាបាលល្អបំផុត ដោយវេជ្ជបណ្ឌិតដ៏ល្បីបំផុតក្នុងលោក
សូមទាក់ទងមជ្ឈមណ្ឌល Spiegel

617-566-3223

THE SPIEGEL CENTER, 1200 Boylston Street, Chestnut Hill, MA 02467
www.drspiegel.com



# ការវិភាគ

របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

## ហេតុអ្វីបានជាជនផ្តាច់ការត្រូវពលរដ្ឋផ្តួលរំលំ

លោក **មូអាំម៉ា ហ្កាដាហ្វី** ( Muammar Gaddafi )ប្រធានាធិបតីនៃប្រទេស**លីប៊ី** ដែលត្រូវប្រជាពលរដ្ឋផ្តួលរំលំ រហូតកាត់ទោសប្រហារជីវិតដោយ**ព្យួរក** និងលោក **សាដាម ហ៊ូសសេន** (Saddam Hussein) ប្រធានាធិបតីនៃប្រទេស **អ៊ីរ៉ាក់** ត្រូវពលរដ្ឋផ្តួលរំលំ ចាប់បានហើយធ្វើឃាត នៅពេលដែលច្បាំងជាមួយពលរដ្ឋខ្លួនឯង។ ហេតុដែលនាំឲ្យពលរដ្ឋនៃប្រទេសទាំងពីរផ្តួលរំលំ ព្រោះ អំពើផ្តាច់ការរបស់អ្នកទាំងពីរ បំបិទសេរីភាពគ្រប់បែបយ៉ាង ពលរដ្ឋមានស្លាប់ជាច្រើនជាបន្តបន្ទាប់គ្នា ដែលក្រោកឡើងប្រឆាំងនឹងអំពើសាហាវឃោរឃៅនៃអ្នកទាំងពីរ។ កាន់អំណាចយូរកន្លងមក ហើយទៅមុខទៀតគ្មានពេលកំណត់ បានជាពលរដ្ឋរើបំរះចេញពីជនផ្តាច់ការទាំងពីរនេះ ដើម្បីសេរីភាពពិតប្រាកដ។ ពិតមែនហើយ គេមើលពីក្រៅហាក់ដូចប្រទេសទាំងពីរនេះ បានសុខសាន្តគ្មានចម្បាំង ប៉ុន្តែទុក្ខវេទនារបស់ពលរដ្ឋមានទម្ងន់ដ៏ខ្លាំង ទ្រាំលែងបានក៏ក្រោកឡើងរួមគ្នាធ្វើបដិវត្តផ្តួលរំលំជនទាំងពីរនាក់នេះទៅ។ ក្រោយមកមានរកាំរកូសខ្លះដោយការបញ្ចេញសេរីភាព មិនទាន់មានឯកភាពជាតិ ថ្ងៃណាមួយអាចបង្រួបបង្រួមជាតិបានប្រកបដោយសេរីភាពនិងការគោរពសិទ្ធិមនុស្ស។ចំណែកលោក **ប៊ីសា អាល់ អសាដ** (Bishar al Assad) ប្រធានាធិបតីនៃប្រទេស **ស៊ីរី** (Syria) ត្រូវពលរដ្ឋដេញចេញពីអំណាច ប៉ុន្តែមិនព្រមចុះចេញ បែរជាយកទ័ពទៅប្រឆាំងនឹងពលរដ្ឋវិញ។ លទ្ធផលឥឡូវនេះ ពលរដ្ឋត្រូវបាត់បង់ជីវិតអស់៣សែននាក់ហើយពលរដ្ឋភៀសខ្លួនរាប់លាននាក់។ នេះពុំមែនកំហុសលើពលរដ្ឋទេ គឺកំហុសនៅលើប្រធានាធិបតីនេះ ដែលពុំព្រមធ្វើពលីកម្មសុខចិត្តចាកចេញពីតំណែងដើម្បីកុំឲ្យពលរដ្ឋច្បាំងគ្នា ឲ្យពលរដ្ឋស្លាប់រក្សាតំណែង។

ហេតុដែលនាំឲ្យប្រទេសប្រជាធិបតេយ្យ ដូចជាសហរដ្ឋអាមារិក កាណាដា បារាំង អូស្ត្រាលីជាដើម មិនមានបដិវត្តដូចនេះ ព្រោះគេគោរពសិទ្ធិពលរដ្ឋ កាន់របបប្រជាធិបតេយ្យពិតប្រាកដ មិនធ្វើឲ្យពលរដ្ឋក្តៅក្រហាយ កន្លែងណាមានការជិះជាន់ កន្លែងនោះមានការរើបំរះ។ អ្នកកាន់អំណាចខ្មែរកុំភ័យគ្មានបដិវត្តពណ៌ទេ បើគោរពសិទ្ធិពលរដ្ឋឲ្យពិតប្រាកដ គោរពរបបប្រជាធិបតេយ្យឲ្យត្រឹមត្រូវ ពិសេស ការបោះឆ្នោតអាណត្តិទី៦ឆ្នាំ ២០១៧-៨ នេះឲ្យបានត្រឹមត្រូវ។ដូច្នេះបដិវត្តកើតឡើងមិនកើតដោយសារអ្នកដឹកនាំ៕

វត្តខ្មែរកាណាដា,ថ្ងៃ២មីនា២០១៧;www.hoksavann.org;savannhok@yahoo.com
Facebook.com / hoksavann ; youtube.com / hoksavann






ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# រដ្ឋាភិបាលចាត់ទុកតួនាទីប្រធានរបស់លោក កឹម សុខា ថា មិនស្របតាមច្បាប់

**ដោយ បែន សុខហ៊ាន | ថ្ងៃសុក្រ ទី២៤ ខែមីនា ឆ្នាំ២០១៧**

មន្ត្រីក្រសួងមហាផ្ទៃបានឱ្យដឹងថា ការលើកលោក កឹម សុខា ឱ្យធ្វើជាប្រធានគណបក្ស និងមន្ត្រី៣នាក់ទៀតជាអនុប្រធាននោះ បានរំលោភបទបញ្ជាផ្ទៃក្នុងរបស់គណបក្សដោយចេញការគំរាមចាត់វិធានការផ្លូវច្បាប់មិនច្បាស់លាស់ដែលអាចប៉ះពាល់ដល់ការដាក់បេក្ខភាពរបស់គណបក្សប្រឆាំង នៅមុនការបោះឆ្នោតឃុំសង្កាត់នៅខែមិថុនា។

នៅក្នុងលិខិតមួយច្បាប់របស់លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃផ្ញើជូនលោក យឹម សុវណ្ណ ប្រធានគណៈកម្មាធិការប្រតិបត្តិគណបក្សសង្គ្រោះជាតិកាលពីថ្ងៃពុធ លោកបានលើកឡើងពីការរុះរើរបស់គណបក្សនេះដែលបានធ្វើឡើងប្រហែល២សប្តាហ៍បន្ទាប់ពីលោក សម រង្ស៊ី បានលាលែងពីប្រធានគណបក្សនោះ បានរំលោភលក្ខន្តិកៈរបស់គណបក្សនេះផ្ទាល់ដោយអាណត្តិនៅសល់មានរយៈពេលតិចជាង១៨ខែមុនពេលជ្រើសរើសមេដឹកនាំ លុះណាតែតួនាទីនេះនៅទំនេរក្នុងរយៈពេល១៨ខែនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

លិខិតដដែលនេះមិនបានបញ្ជាក់ថា តើរដ្ឋាភិបាលនឹងចាត់វិធានការអ្វីនោះឡើយ ហើយកាលពីម្សិលមិញ លោក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃមានចម្លើយថា ហេតុអ្វីបានជារដ្ឋាភិបាលចាប់អារម្មណ៍ទៅលើការបំពានបទបញ្ជាផ្ទៃក្នុងបក្សនេះ។

ដោយបដិសេធមិនបញ្ជាក់ថាច្បាប់ណាដែលត្រូវបានរំលោភនោះ ឧត្តមសេនីយ៍ ខៀវ សុភ័គ បានមានប្រសាសន៍ថា "ចំណាត់ការ ឬមួយមិនចំណាត់ការក្រសួងមិនមែនជាអ្នកចាត់ការទេតែគឺច្បាប់ជាអ្នកចាត់ការ"។

លោកបានថ្លែងថា "យើងប្រាប់តែប៉ុណ្ណឹងបានហើយ គឺគាត់នឹងយល់។ ឧទាហរណ៍កន្លែងហ្នឹងមានខ្មោច កុំទៅអី កន្លែងហ្នឹងខ្មោច លងតែបើគាត់ទៅ ខ្មោចលងគាត់ទៅ"។

លិខិតដដែលនេះក៏បានសំដៅដល់ពាក្យស្លោកសម្រាប់ប្រើប្រាស់ពេលយុទ្ធនាការឃោសនារបស់គណបក្សប្រឆាំងសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅខែមិថុនាថា "ដូរមេឃុំបម្រើបក្ស ដាក់មេឃុំបម្រើរាស្ត្រ" ផងដែរ។

លោក ស ខេង បានសរសេរថា "ពាក្យស្លោកនេះមានខ្លឹមសារផ្ទុយនឹងស្មារតីរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងឃុំសង្កាត់ ពិសេសរបបប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា និងគោលការណ៍នៃប្រព័ន្ធបោះឆ្នោតសមាមាត្រ"។

ឧត្តមសេនីយ៍ ខៀវ សុភ័គ បានព្រមានថា ពាក្យស្លោកនេះបង្កឱ្យមាន "ការបែកបាក់ជាតិ"។ លោកបានថ្លែងថា "យើងឃើញកន្លងមក មេឃុំបម្រើរាស្ត្រតើ គ្មានមេឃុំបម្រើបក្សឯណា"។

ឧត្តមសេនីយ៍រូបនេះបានមានប្រសាសន៍ថា ក្រសួងមហាផ្ទៃមិនទាន់សម្រេចថា តើមានវិធានការដាក់ទោសទណ្ឌ ឬយ៉ាងណានៅឡើយទេ។

ដោយហាក់ដូចជាងាកទៅធ្វើការប្រៀបធៀបខ្មោចថា ជាច្បាប់នោះ លោកបានមានប្រសាសន៍ថា "ដូរ ឬមិនដូរ វាជារឿងរបស់គាត់"។ "បើខ្មោចលងគឺលងគាត់មិនមែនលងមហាផ្ទៃទេ"។

លោក យឹម សុវណ្ណ ដែលក៏ជាអ្នកនាំពាក្យគណបក្សសង្គ្រោះជាតិផងដែរនោះបានមានប្រសាសន៍កាលពីម្សិលមិញថា គណបក្សបានព្រាងការឆ្លើយតបដោយស្នើសុំជួបប្រជុំជាមួយលោក ស ខេង ឬតំណាងក្រសួងដើម្បីពិភាក្សាអំពីចំណុចដែលបានលើកឡើងក្នុងលិខិតនេះ ប៉ុន្តែបានបដិសេធមិនធ្វើអត្ថាធិប្បាយបន្ថែមទេ។

គណបក្សប្រជាជនកម្ពុជាបានគំរាមប្តឹងលុះណាតែគណបក្សសង្គ្រោះជាតិបានដកពាក្យស្លោកនេះចេញជាផ្លូវការ ដែលរហូតមកទល់ពេលនេះ

**តទៅទំព័រទី ១៧**



Interior Minister Sar Kheng gestures toward deputy opposition leader Kem Sokha in 2015 at the National Assembly in Phnom Penh, where the two met to discuss recent political issues. (Siv Channa/The Cambodia Daily)

# GOVERNMENT DEEMS KEM SOKHA'S PRESIDENCY ILLEGITIMATE

**by Ben Sokhean | March 24, 2017**

Interior Ministry officials said the CNRP's promotion of Kem Sokha to party president and three officials to vice president violated internal party rules, issuing vague threats of legal consequences that could potentially imperil the standing of the opposition party's candidates ahead of June commune elections.

In a letter sent on Wednesday by Interior Minister Sar Kheng to CNRP executive committee chairman Yim Sovann, he said the party's reshuffle, which came about two weeks after Sam Rainsy resigned as party president, violated the party's own bylaws, which mandates an 18-month gap before selecting the leader unless the position becomes vacant within 18 months of a national election.

The letter did not specify what action the government would take, and ministry spokesman KhieuSopheak on Thursday was cryptic about why the internal infraction merited government attention.

"Whether they take action or not, it's not the ministry's decision, but it is in the law," General Sopheak said, declining to specify which law-if any-had allegedly been violated.

"What we told them is enough," he said. "They will understand it. For example: There is a ghost in there, please don't go inside. If you go, the ghost will haunt you."

The letter also took aim at the opposition's campaign slogan for upcoming June commune elections: "Change commune chiefs who serve the party and replace them with commune chiefs who serve the people."

"This slogan has content that violates the principle of 1993 Constitution, Law on Political Parties, Law on the Election of Commune/Sangkat Council, Law on the Administration of Commune /Sangkat, and especially liberal multi-party democracy in Cambodia and the principle of a proportional [electoral] system," Mr. Kheng wrote.

Gen. Sopheak warned that the slogan would cause "national disintegration."

"We just see commune chiefs who serve the people," he said. "There are no commune chiefs who serve the party."

The general said the ministry had yet to decide whether it would back its "advice" with punitive consequences.

"Change it or not, it is their issue," he said, seeming to return to the metaphor of ghosts for the law. "If the ghosts haunt, they're the ones who will haunt you, not the Interior Ministry."

Mr. Sovann, who is also the CNRP's spokesman, said on Thursday that the party had drafted a response requesting to meet with Mr. Kheng or a ministry representative, but declined to comment further.

When the party rushed to appoint Mr. Sokha and his three deputies earlier this month, they did so because the Law on Political Parties requires a permanent president to endorse commune councilor candidates whose names had to be sent to the election committee by the first weekend of the month, according to one of those new deputies, CNRP lawmaker Mu Sochua.

If the government were to deem Mr. Sokha's presidency illegitimate, the submission of those candidates might become invalid, said political analyst Cham Bunthet, who believed the opposition's position in the June elections was doomed one way or another.

"If [the CPP] allows the CNRP in this election, they could lose half of their grassroots power," he said,

adding that the ruling party might invite the opposition back to the negotiating table to quiet international criticism after the vote.

"It's a very smart, very evil game," he said. "That's how politics are played in this country."

(Additional reporting by Ben Paviour)

sokhean@cambodiadaily.com

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# គណបក្សសង្គ្រោះជាតិរៀនរស់ដោយសារខ្លាច គណបក្សកាន់អំណាចរម្លាយចោលក្រោមច្បាប់ថ្មី

**ដោយហ្សូមបិរ ភីធីរ៍ | ថ្ងៃព្រហស្បតិ៍ ទី១៦ខែមីនា ឆ្នាំ២០១៧**

កាលពីដើមសប្តាហ៍នេះគណបក្សសង្គ្រោះជាតិបានចុះឈ្មោះបេក្ខជនចំនួន១១.៥៧២រូប សម្រាប់ការបោះឆ្នោតឃុំសង្កាត់នៅខែមិថុនា នៅក្នុងអ្វីដែលទំនងជាបង្ហាញពីសូចនាករសម្រាប់ការបោះឆ្នោតជាតិដ៏សំខាន់នៅឆ្នាំក្រោយ ។

ប៉ុន្មានថ្ងៃក្រោយមក លោក សាយ ឈុំ ប្រធានព្រឹទ្ធសភា និងជាមន្ត្រីដ៏ស្មោះស្ម័គ្រនឹងគណបក្សប្រជាជនកម្ពុជាដែលកាន់អំណាចដុះស្លែនោះបានចុះហត្ថលេខាលើវិសោធនកម្មច្បាប់ដែលផ្តល់អំណាចថ្មីដ៏ទូលំទូលាយដល់រដ្ឋាភិបាលក្នុងការកម្ចាត់គណបក្សនយោបាយណាមួយពាក់ព័ន្ធការប្រព្រឹត្តបទល្មើសនានាដែលមិនបានចែងច្បាស់លាស់ ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលប្រឈមនឹងការសាកល្បងដ៏តឹងតែងបំផុតនៅក្នុងរយៈពេល២៥ឆ្នាំមកនេះ បានវាយប្រហារឥតអៀនខ្មាសលើគណបក្សសង្គ្រោះជាតិនៅពេលលោកបានចេញបទបញ្ជាឱ្យគណបក្សរបស់លោករៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយកាលពីខែមុន ។

វាបានធ្វើឱ្យអ្នកសង្កេតការណ៍នៅមានចម្ងល់ថាតើគណបក្សសង្គ្រោះជាតិនឹងតស៊ូរស់រហូតដល់ការបោះឆ្នោតឃុំសង្កាត់បានឬមិនបាន កុំថាឡើយដល់ទៅការបោះឆ្នោតជាតិឆ្នាំ២០១៨ ។ ប្រសិនបើបានក្រុមអ្នកសង្កេតការណ៍នេះបានលើកឡើងថា គណបក្សប្រឆាំងនេះត្រូវបន្ទន់ជំហររបស់ខ្លួនដែលធ្លាប់តែប្រើប្រាស់ពាក្យពេចន៍ធ្ងន់ៗក្នុងការឃោសនាជួនកាលនិយាយពាក់ព័ន្ធដល់ជាតិសាសន៍ទៀតផងនោះ ។ ប៉ុន្តែគណបក្សនេះ អាចបាត់បង់សំឡេងឆ្នោតសម្រេចជោគវាសនាមួយចំនួន ។

គណបក្សសង្គ្រោះជាតិបានចាប់ផ្តើមមានការប្រុងប្រយ័ត្នរួចហើយក្នុងការប្រើពាក្យពេចន៍របស់ខ្លួន ។

លោក កឹម សុខា ប្រធានគណបក្សសង្គ្រោះជាតិបាននិងកំពុងប្រាប់សមាជិករបស់ខ្លួនឱ្យមានការអត់ធ្មត់កុំធ្វើការវាយប្រហារដោយផ្ទាល់ខ្លួនលើរដ្ឋាភិបាល និងឥស្សរជនគណបក្សប្រជាជនកម្ពុជា ។ កាលពីថ្ងៃអង្គារនៅឯកិច្ចប្រជុំមួយធ្វើឡើងទុកសម្រាប់ការបោះឆ្នោតឃុំសង្កាត់នោះ លោកបានណែនាំបេក្ខជនក្នុងគណបក្សរបស់លោកកុំឱ្យនិយាយពាក់ព័ន្ធនឹងថ្ងៃ៧មករា ឆ្នាំ១៩៧៩ ជាថ្ងៃដែលធ្វើឱ្យប្រជាពលរដ្ឋខ្មែរជាច្រើនមានការបកស្រាយខុសៗគ្នាថា ជាថ្ងៃដែលវៀតណាមបានរំដោះប្រទេសពីកណ្តាប់ដៃខ្មែរក្រហម ឬជាថ្ងៃដែលវៀតណាមចូលត្រួតត្រាកម្ពុជារយៈពេល ១០ឆ្នាំ ដែលអំឡុងពេលនោះប្រទេសនេះបានលើកបន្តុបគណបក្សប្រជាជនកម្ពុជាឱ្យកាន់អំណាច ។

លោក មាស នី អ្នកវិភាគនយោបាយបានលើកឡើងថា គណបក្សប្រឆាំងត្រូវតែតស៊ូទៅមុខទៀត ។

ច្បាប់ស្តីពីគណបក្សនយោបាយដែលទើបតែធ្វើវិសោធនកម្មអនុញ្ញាតឱ្យក្រសួងមហាផ្ទៃ និងតុលាការកំពូលដែលមជ្ឈដ្ឋានទូទៅមើលឃើញថា ជាឧបករណ៍របស់គណបក្សប្រជាជនកម្ពុជានោះផ្អាកសកម្មភាព ឬរម្លាយគណបក្សណាមួយចោលពាក់ព័ន្ធការប្រព្រឹត្តបទល្មើសនានាដែលមិនមានចែងច្បាស់លាស់ ក្នុងនោះមានដូចជា "ការធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យសេរីពហុបក្ស"និង"ការញុះញង់ដែលអាចនាំឱ្យមានការបែកបាក់ជាតិ" ។ គណបក្សប្រជាជនកម្ពុជាបានគំរាមប្តឹងគណបក្សសង្គ្រោះជាតិរួចហើយពីបទញុះញង់ពាក់ព័ន្ធពាក្យស្លោកឃោសនាដែលជំរុញឱ្យអ្នកបោះឆ្នោតប្តូរមេឃុំបម្រើបក្សដាក់មេឃុំបម្រើរាស្ត្រ ។

រហូតមកទល់ពេលនេះគណបក្សសង្គ្រោះជាតិនៅតែរក្សាជំហរដដែលដោយបដិសេធមិនបោះបង់ចោលពាក្យស្លោកនេះឡើយ ។ ប៉ុន្តែលោក មាស នី បានលើកឡើងថា គណបក្សនេះទំនងជាអត់ធ្មត់មិននិយាយអ្វីដែលពាក់ព័ន្ធនឹងថ្ងៃ៧មករានោះឡើយ ។ **តទៅទំព័រទី១៥**



The opposition CNRP's new leadership stands before a party congress in Phnom Penh in March From left: Kem Sokha, Pol Ham, Mu Sochua and Eng Chhay Eang. (Emil Kastrup/The Cambodia Daily)

**Continued from page 01**

# OPPOSITION LEARNING ...

of a century, unabashedly put the CNRP in his crosshairs when he ordered his party to draw up the amendments to the Law on Political Parties last month.

That has observers wondering whether the CNRP will live to see the commune elections at all, let alone the national poll next year. If it does, they say the opposition will have to drastically tone down its often fiery-sometimes racist-campaign talk. But it could also lose some critical swing votes in the process.

The CNRP has already started watching its words.

Party President Kem Sokha has been urging members to refrain from personal attacks on government and CPP figures. On Tuesday, at a prep meeting for the local elections, he instructed the party's candidates to avoid talk of January 7, 1979, a date that politically divides many Cambodians as the day Vietnam either liberated the country from the Khmer Rouge or embarked upon a 10-year occupation during which its officials installed the CPP.

Meas Nee, a political analyst, said the opposition will have to go even further.

The amended party law allows the Interior Ministry and Supreme Court, widely seen as a CPP tool, to suspend or dissolve parties for a new list of vague offenses, including "subversion of liberal multiparty politics" and "incitement that would lead to national disintegration." The CPP has already threatened to sue the CNRP for incitement over a campaign slogan urging voters to replace commune councilors who serve the party with those who serve the people.

The CNRP has so far held firm, refusing to abandon the slogan. But Mr. Nee said the party was likely to refrain from more than just talk of January 7.

"In the past, slogans against the Vietnamese could be accused by the ruling party as discriminative, but this time they can be accused as creating… incitement," he said.

In the lead-up to the 2013 national elections, the CNRP whipped up some support by harping on popular suspicions that the government has willingly given up territory in the long-running demarcation of Cambodia's frontier with Vietnam.

It has proved an especially sore point for the CPP, which seems to recognize that its historic ties with Hanoi are a genuine political liability. CNRP lawmakers would draw large, angry crowds on trips to the border and pepper their speeches with liberal invectives against "yuon" encroachment and migration. Many consider the word a derogatory epithet for the Vietnamese, though the CNRP disagrees.

"[The] CNRP might need to adjust its tactics by not mentioning the word 'Vietnamese' directly, by spelling out policy that can address the issue of migrants in general," Mr. Nee said. "[O]nly referring to all migrants could… make people understand who they refer to.

This way the CPP might find it difficult to accuse [the opposition of] inciting propaganda."

KoulPanha, who runs the non-government Committee for Free and Fair Elections, said the opposition has already softened its talk on border issues since two of its lawmakers were arrested and convicted on related charges over the past two years.

With the new party law now in force, he said, "I expect the tone to get even more soft."

That's not likely to turn off most CNRP supporters, Mr. Panha said, but it could cost the party votes from those on the fence who might instead cast their ballots for someone else or, more likely, no one at all. Those votes could prove critical in provinces with tight races, and every seat in the 123-seat National Assembly is precious. Had the CNRP and CPP swapped only seven seats in 2013, the opposition would have won.

**Continued to Page 15**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# នាយករដ្ឋមន្ត្រីថា តំណែងយ៉ាងច្រើនរបស់ លោក សុខ អាន នឹងត្រូវបែងចែកឱ្យក្រសួងពាក់ព័ន្ធ

**ដោយ ឃួន ណារិម និង ខូលីន ម៉ីយន៍ | ថ្ងៃព្រហស្បតិ៍ ទី២៣ ខែមីនា ឆ្នាំ២០១៧**

លោក ហ៊ុន សែន ស្តីបន្ទោសអ្នកនាំពាក្យរដ្ឋាភិបាលធ្ងន់ៗដែលប្រាប់ប្រព័ន្ធផ្សព្វផ្សាយផ្ទុយពីនេះ កាលពីម្សិលមិញ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា មុខតំណែងយ៉ាងច្រើនរបស់ឧបនាយករដ្ឋមន្ត្រី សុខ អាន នឹងត្រូវបែងចែកឱ្យទៅក្រសួងមួយចំនួនដោយកែពាក្យសម្តីរបស់អ្នកនាំពាក្យរដ្ឋាភិបាលម្នាក់ដែលបានលើកឡើងនៅសប្តាហ៍នេះថា មុខតំណែងរបស់លោករក្សាទុកឱ្យនៅដដែល។

ដូចលោក សុខ អាន ដែរ ឧបនាយករដ្ឋមន្ត្រី ប៊ិន ឈិន ជាមន្ត្រីជំនាញ និងជាអ្នកចរចាដែលលោក ហ៊ុន សែន ជឿទុកចិត្តបំផុតជាយូរមកហើយ ត្រូវបានតែងតាំងឱ្យជំនួសតំណែងលោក សុខ អាន ជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី១៦ ខែមីនា ពោលគឺមួយថ្ងៃបន្ទាប់ពីលោក សុខ អាន ទទួលមរណភាពនៅប្រទេសចិន។

កាលពីថ្ងៃអង្គារ៍លោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីបានលើកឡើងថា លោក ប៊ិន ឈិន វ័យ៦៧ឆ្នាំ ក៏នឹងក្លាយជាប្រធានទីភ្នាក់ងារផ្សេងៗទៀតដែលធ្លាប់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក សុខ អាន ផងដែរដូចជា អាជ្ញាធរអប្សរាក្រុមការងារពិសេសរបស់រដ្ឋាភិបាលទទួលបន្ទុកគ្រប់គ្រងសាលាក្តីខ្មែរក្រហមសមាគមកាយឫទ្ធិ និងរាជបណ្ឌិត្យសភាកម្ពុជាជាដើម។

លោក ហ៊ុន សែន បានស្តីបន្ទោសលោក ផៃ ស៊ីផាន ធ្ងន់ៗជាសាធារណៈអំឡុងសុន្ទរកថាកាលពីម្សិលមិញថ្លែងទៅកាន់ក្រុមគរុសិស្សដែលបញ្ចប់ការសិក្សានៅវិទ្យាស្ថានជាតិអប់រំក្នុងរាជធានីភ្នំពេញ ហើយបានប្រកាសថា ភាគច្រើននៃស្ថាប័នរដ្ឋទាំងនេះនឹងត្រូវបែងចែកឱ្យទៅក្រសួងពាក់ព័ន្ធរួមជាមួយថវិការបស់ស្ថាប័នទាំងនេះដែលពីមុនទម្លាក់ឱ្យទៅទីស្តីការគណៈរដ្ឋមន្ត្រីផងដែរ។

លោកនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា "ខ្ញុំសោកស្តាយដែលឯកឧត្តម ផៃ ស៊ីផាន បានធ្វើរឿងនេះ" ដើម្បីសំដៅដល់បទសម្ភាសន៍ជាមួយស្ថាប័នប្រព័ន្ធផ្សព្វផ្សាយនានាដែលក្នុងនោះអ្នកនាំពាក្យរូបនេះបានលើកឡើងថា មុខតំណែងទាំងអស់របស់លោក សុខ អាន នឹងត្រូវប្រគល់ឱ្យទៅលោក ប៊ិន ឈិន តែម្នាក់។

លោក ហ៊ុន សែន បានបន្ថែមទៀតថា "មានពេលខ្លះ មិនមែនអ្នកសារព័ត៌មានខុសទេ ប៉ុន្តែយើងជាអ្នកផ្តល់ព័ត៌មានឱ្យគេខុស"។ (កាសែត ខេមបូឌា ដេលី បានចុះផ្សាយដំណឹងទំព័រមុខមួយកាលពីថ្ងៃអង្គារស្តីពីការផ្ទេរអំណាចឱ្យទៅលោក ប៊ិន ឈិន ផ្អែកតាមបទសម្ភាសន៍ជាមួយលោក ផៃ ស៊ីផានច)។

លោក ហ៊ុន សែន មានប្រសាសន៍ថា "ខ្ញុំបាននិយាយហើយថា ធ្វើអ្នកនាំពាក្យក្តីធ្វើអ្នកកាសែតក្តីធ្វើអ្នកអត្ថាធិប្បាយក្តី កុំជោរ កុំធ្វើឯងជាអ្នកចេះគ្រប់រឿង"។

លោកបញ្ជាក់ថា លោក ផៃ ស៊ីផាន ដែល

តទៅទំព័រទី ១៧



លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជជែកកាលពីម្សិលមិញជាមួយលោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនៅពិធីបុណ្យសពលោកឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលបានទទួលមរណភាពកាលពីថ្ងៃពុធ។
រូបថត: ស៊ីវ ចាន់ណា,ឌឹ ខេមបូឌា ដេលី

# SOK AN'S FIEFDOM TO BE SPLIT UP, HUN SEN SAYS

Prime Minister Chides government spokesman for telling media otherwise

**by KhuonNarim and Colin Meyn | March 23, 2017**

Reversing the course of "continuity" laid out by a government spokesman this week, Prime Minister Hun Sen on Wednesday declared that the sprawling portfolio of Deputy Prime Minister SokAn would be spread among ministries.




Deputy Prime Minister Sok An speaks to journalists in 2008. (Reuters)

Deputy Prime Minister Bin Chhin, who like SokAn has long been one of Mr. Hun Sen's most trusted technocrats and negotiators, was appointed to replace Sok An as head of the Council of Ministers on March 16, the day after his predecessor died in China.

On Tuesday, Council of Ministers spokesman PhaySiphan said that Mr. Chhin, 67, would also head various other agencies that had been under the control of Sok An, such as the Apsara Authority, the government's task force for the Khmer Rouge tribunal, the Scouts and the Royal Academy of Cambodia.

Mr. Hun Sen chided Mr. Siphan during his speech on Wednesday in front of a graduating class of teachers at the National Institute of Education in Phnom Penh and announced that most of the state institutions would in fact be divvied out to relevant ministries, along with the budget for those bodies, which previously went to the Council of Ministers.

"I regret that High Excellency PhaySiphan did this work," the prime minister said, referring to interviews with various media outlets in which the spokesman said SokAn's entire portfolio would be given to Mr. Chhin.

"Sometimes the reporter is not wrong, but we have provided the wrong information," he said. (The Cambodia Daily published a front-page story on Tuesday about the transfer of power to Mr. Chhin based on an interview with Mr. Siphan.)

"I have already told spokesmen, reporters and commentators not to pretend that you know everything," he added.

Mr. Hun Sen said that Mr. Siphan, also a secretary of state at the Council of Ministers, had jumped the gun by announcing decisions that had not been settled on by his superiors.

"The boss had not yet decided, but it was released," he said, adding that Mr. Siphan would not be disciplined but needed to take the prime minister's speech as medicine to prevent future missteps.

"Now cure your craziness with this injection," he said.

Upon completing his scolding, Mr. Hun Sen laid out how SokAn's various posts would be shared among ministries.

Both the Apsara Authority, which oversees the Angkor Archaeological Park, **Continued to Page 17**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# បក្សប្រជាជនសន្យាផ្តល់ប្រាក់ខែដល់មន្ត្រី ឃុំសង្កាត់ដែលពុំជាប់ឆ្នោត

**ដោយ បែន សុខហ៊ាន | ថ្ងៃច័ន្ទ ទី២៧ ខែមីនា ឆ្នាំ២០១៧**

បន្ទាប់ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើជាអធិបតីក្នុងកិច្ចប្រជុំបិទទ្វារមួយនៅរាជធានីភ្នំពេញ ជាមួយមន្ត្រីមូលដ្ឋានរបស់គណបក្សប្រជាជនកម្ពុជាទូទាំងរាជធានីអ្នកនាំពាក្យគណបក្សកាន់អំណាចបានបញ្ជាក់ថា មន្ត្រីឃុំសង្កាត់ដែលបាត់បង់អាសនៈរបស់ខ្លួននៅក្នុងការបោះឆ្នោតក្នុងពេលដ៏ខ្លីខាងមុខនឹងនៅតែបន្តទទួលបានប្រាក់ខែពីគណបក្សប្រជាជន។

មន្ត្រីមូលដ្ឋានដែលបានចូលរួមការប្រជុំកាលពីម្សិលមិញនៅកោះពេជ្រ បានលើកឡើងថា លោកនាយករដ្ឋមន្ត្រីបានឆ្លៀតឱកាសក្នុងកិច្ចប្រជុំនេះជំរុញឱ្យពួកគាត់ខិតខំធ្វើការបម្រើប្រជាពលរដ្ឋ និងឈ្នះការបោះឆ្នោតរបស់ខ្លួនដែលនឹងប្រព្រឹត្តទៅនឹងថ្ងៃទី៤ ខែមិថុនា។

អ្នកស្រី យិន ណារុំ ជាមន្ត្រីខណ្ឌច្បារអំពៅ បានថ្លែងថា "សម្តេចនាយកឱ្យ ហ៊ុន សែន" ផ្តាំផ្ញើឱ្យយើងផ្សព្វផ្សាយណែនាំក្រុមគ្រួសារយើងឱ្យទៅបោះឆ្នោតឱ្យបានទាំងអស់គ្នា ដើម្បីកុំឱ្យបក្សផ្សេងបំបែកបំបាក់យើងបាន"។

ទោះជាយ៉ាងណាក្នុងពេលជាមួយគ្នានេះ គណបក្សកាន់អំណាចក៏ហាក់ដូចត្រៀមខ្លួនសម្រាប់ការបរាជ័យនៅក្នុងការបោះឆ្នោតឃុំ-សង្កាត់ ដែលខ្លួនមានប្រៀបយ៉ាងខ្លាំងកាលពីឆ្នាំ២០១២ ដោយឈ្នះ១.៥៩២ឃុំសង្កាត់ ក្នុងចំណោមឃុំសង្កាត់ទាំង១.៦៣៣នៅទូទាំងប្រទេស។

លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានមានប្រសាសន៍កាលពីម្សិលមិញថា មន្ត្រីឃុំ-សង្កាត់ ដែលបាត់បង់តំណែងរបស់ខ្លួននឹងទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែស្មើនឹងប្រាក់ខែរបស់ពួកគាត់។

លោកបានលើកឡើងថា "យើងនៅតែគិតគូរគាត់ជាមន្ត្រីរបស់បក្ស ហើយមានការឧបត្ថម្ភចំពោះជីវភាពរស់នៅ ជាពិសេសប្រាក់បំណាច់ប្រចាំខែ" ហើយថា លោកមិនបានចូលរួមការប្រជុំកាលពីម្សិលមិញទេ។

អ្នកនាំពាក្យរូបនេះពន្យល់ថា "បំណាច់ហ្នឹងមានន័យថា ចៅសង្កាត់ ឬមេឃុំបានប៉ុន្មាន យើងឧបត្ថម្ភគាត់ចំនួនប៉ុណ្ណឹងដែរ"។

ការអត្ថាធិប្បាយរបស់លោក សុខ ឥសាន ស្រដៀងគ្នាទៅនឹងផែនការមួយដែលបានគូសបញ្ជាក់ក្នុងសារាចរណែនាំមួយចុះថ្ងៃទី១៦ ខែកុម្ភៈ និងចុះហត្ថលេខាដោយឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន ដែលក្នុងនោះលោកស្រីបានបញ្ជាឱ្យការិយាល័យនានារបស់រដ្ឋាភិបាលផ្តល់ការងារដល់មន្ត្រីឃុំ-សង្កាត់ ដែលពុំជាប់ឆ្នោត ឬដែលមិនជាប់ឈ្មោះក្នុងបញ្ជីបេក្ខជនសម្រាប់ការបោះឆ្នោតនៅឆ្នាំនេះ។ នៅក្នុងសារាចរដែលសរសេរតាងនាមលោក ហ៊ុន សែន នេះលោកស្រីបានលើកឡើងថា" ប្រធានស្ថាប័នរដ្ឋត្រូវទទួលយក



លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ពេលចូលរួមជាអធិបតីក្នុងកិច្ចប្រជុំមួយ កាលពីម្សិលមិញនៅកោះពេជ្រ ជាមួយមន្ត្រីមូលដ្ឋានមកពីទូទាំងរាជធានីភ្នំពេញ។ Fresh News

មេឃុំ ចៅសង្កាត់ជំទប់ទី១ជំទប់ទី២ និងសមាជិកក្រុមប្រឹក្សាដែលមិនបានជាប់ឈ្មោះនៅអាណត្តិឆ្នាំ២០១៧?ដោយធ្វើការតែងតាំងជាជំនួយការ"។

សារាចរណែនាំនេះបញ្ជាក់ថា ប្រាក់ខែរបស់អតីតមេឃុំ ចៅសង្កាត់ គឺស្មើនឹងប្រាក់ខែរបស់អនុប្រធាននាយកដ្ឋានជំទប់ទទួលបានប្រាក់ខែស្មើប្រធានការិយាល័យសមាជិកក្រុមប្រឹក្សាទទួលបានប្រាក់ខែស្មើអនុប្រធានការិយាល័យ។

លោក សុខ ឥសាន បានមានប្រសាសន៍កាលពីម្សិលមិញថា គណបក្សនឹងប្រើប្រាស់ប្រាក់របស់ខ្លួនដើម្បីឧបត្ថម្ភមន្ត្រីដែលបាត់បង់ការងាររបស់ខ្លួន បន្ទាប់ពីការបោះឆ្នោតប៉ុន្តែគេមិនច្បាស់ទេថា?តើលក្ខខណ្ឌនេះពិតឬក៏អត់សម្រាប់អ្នកដែលមិនជាប់ឈ្មោះក្នុងបញ្ជី។

គណបក្សកាន់អំណាចបានជំទាស់យ៉ាងខ្លាំងទៅនឹងពាក្យស្លោកយុទ្ធនាការឃោសនា "ដូរមេឃុំបម្រើបក្ស?ដាក់មេឃុំបម្រើរាស្ត្រ"របស់គណបក្សសង្គ្រោះជាតិនៅមុនការបោះឆ្នោត។

ក្រសួងមហាផ្ទៃបានបញ្ជាក់កាលពីសប្តាហ៍មុនថា ពាក្យស្លោកនេះខុសច្បាប់។ គណបក្សសង្គ្រោះជាតិមិនទាន់បញ្ជាក់ថាតើខ្លួននឹងលុបចោលពាក្យស្លោកនេះ ឬយ៉ាងណាទេ ប៉ុន្តែមន្ត្រីគណបក្សប្រឆាំងបានបង្ហាញថា គណបក្សនឹងដកវាចេញវិញ៕ **សុខុម**

# COMMUNE ELECTION LOSERS TO KEEP SALARIES, RULING PARTY SAYS

**by Ben Sokhean | March 27, 2017**

After Prime Minister Hun Sen presided over a closed-door meeting in Phnom Penh on Sunday with local ruling party officials from across the city, a ruling party spokesman said commune officials who lose their seats in upcoming elections would continue to be paid by the party.

Local officials who attended Sunday's meeting at the Koh Pich auditorium said the prime minister used the meeting to encourage them to work hard to serve the people and win their commune elections on June 4.

"Samdech [Mr. Hun Sen] sent the message to disseminate and advise our family members to go vote, and don't let the other party dilute our voice," said Yin Narom, a Chbar Ampov district official.

At the same time, however, the ruling party also seems prepared for losses in the local elections that it dominated in 2012, winning 1,592 out of 1,633 communes nationwide.

CPP spokesman SokEysan said on Sunday that commune-level officials who lose their positions would be guaranteed a monthly payment equal to their salary.

"We will consider them as party officials and will support their living conditions, especially by providing their salaries," Mr. Eysan said, adding that he had not attended Sunday's meeting.

"It means that however much the commune chief receives [in wages], we will donate the same amount to them," the spokesman explained.

Mr. Eysan's comments are similar to a plan outlined in a directive dated February 16 and signed by Deputy Prime Minister Men Sam An, in which she told government offices to hire commune officials who fail to get elected or are left off the candidate list for this year's election.

In that directive, written on behalf of Mr. Hun Sen, she said "directors of state institutions must accept commune chiefs, first deputy commune chiefs, second deputy commune chiefs and commune councilors whose names are not in the list of the 2017 mandate and appoint them as assistants."

The directive says that the salaries of former commune chiefs should be equal to a deputy department director; deputy commune chiefs equal to bureau chiefs, and commune councilors equal to deputy bureau chiefs.

Mr. Eysan said on Sunday that party money would be used to support officials who lose their jobs after the elections, though it was unclear if the same was true for those who were not placed on the ballot.

The ruling party has come out hard ahead of the elections against the CNRP's campaign slogan: "Change commune chiefs who serve the party and replace them with commune chiefs who serve the people."

Interior Minister Sar Kheng said last week that the slogan was illegal.

The CNRP has yet to announce whether it will drop the slogan, though opposition officials have indicated that the party will back down.

## តមកទំព័រទី ០១ រាត្រី "ក្រមា" នៅលីនរដ្ឋម៉ាសាឈូសេត...

រាងកាយជាអង្រឹងសម្រាប់កូនដេកជាផ្លឹតសម្រាប់បក់... រាប់គុណប្រយោជន៏មិនអស់។ ក៏ប៉ុន្តែនាឆ្នាំ១៩៧៥ នាឱកាសជ័យជំនះក្រុមខ្មែរក្រហមលើកម្ពុជា, ក្រុមនោះបានប្រើក្រម៉ាជាកន្សែកបង់ករ ហើយសំគាល់ថា បង់ក ក្រម៉ា គឺជាក្រុមបក្សនយោបាយកុម្មុយនិស្តរបស់គេ។ នៅពេលគេដឹងថា ក្រុមនេះបានធ្វើការកាប់សម្លាប់ជនជាតិខ្លួនឯងនឹងជនបរទេសយ៉ាងកាចសាហាវមកកេរឈ្មោះដ៏មានប្រយោជន៏របស់ក្រម៉ាក៏បានបាត់បង់ធ្វើឱ្យខ្មែរលែងហ៊ានប្រើក្រម៉ាយ៉ាងចេញមុខដូចពេលមុនៗ បើទោះជាក្រម៉ានៅតែជារបស់ប្រើប្រាស់ដ៏ចាំបាច់របស់ខ្មែរក៏ដោយ។

នា១០-២០ឆ្នាំចុងក្រោយនេះប្រជាពលរដ្ឋចាប់ផ្ដើមប្រើរើបៗឡើងវិញ រីឯខ្មែរនៅឯបរទេសក៏បានមើលឃើញនឹងឱ្យតម្លៃក្រម៉ាយ៉ាងខ្លាំងមកវិញ។ រៀបចំដោយសមាគមខ្មែរ KCPC,រាត្រី "ក្រម៉ា"គឺប្រាកដជាការប៉ុនប៉ងលើកកំពស់ក្រណាត់សំពត់៤ជ្រុងទ្រវែងក្រឡាចត្រង់ដ៏ស្ដើងទន់រំភើយនេះឡើងវិញ ដោយយកក្រម៉ាមកកាត់ជាអាវច្រើនឈុតជាកន្សែងបង់ករ-ជាកន្សែងសម្រាប់ស្រីពាក់ឈៀង...ហើយទាំងអស់គ្នា នាយប់នោះយ៉ាងហោចណាស់



ក៏មានក្រមារបង់ករមួយម្នាក់សម្រាប់អួតដាក់គ្នាដែរ។

លោកសមាជិកក្រុមប្រឹក្សាក្រុងលីនហុង ណេត ជាខ្មែរអាមេរិកាំងដំបូងបង្អស់ដែលបានជាប់ឆ្នោតតាំងពី៥-៦ឆ្នាំមុនជាមួយនឹងភរិយា ក៏បានមកចូលរួមរៀបចំញាំងឱ្យពិធីនេះមានភាពអធិកអធមនឹងរីករាយក្រៃលែង។ នៅ លីន មានសហគមន៏ខ្មែរប្រមាន៥-៦ពាន់គ្រួសារ តែមានវត្តអារាម២កន្លែងសម្រាប់ធ្វើបុណ្យនឹងមានទីផ្សារខ្មែរធំៗ មានភោជនីយដ្ឋានម្ហូបខ្មែរ






បើប្លកគ្នានឹងក្រុង"រីវៀ"នៅជាប់គ្នានោះ គឺជាតំបន់មាត់សមុទ្រដ៏សម្បូរខ្មែររស់នៅច្រើនជាងគេនាឆ្នេរខាងកើតសហរដ្ឋអាមេរិកបន្ទាប់ពីឡូវែលមក។

គណកម្មការបានប្រកាសថា ពិធីបុណ្យចូលឆ្នាំរការនៅលីននឹងប្រារព្ធនៅថ្ងៃសៅរ៍ ទី២៩ មេសាឆ្នាំ២០១៧ នៅឱទ្យានមុខសាលាក្រុងលីន៕

## ទឹកដោះគោ + ប៉េងប៉ោះ ផ្ទៃមុខអ្នកនឹងសម៉ត់រលោងស្អាតត្រឹមរយះពេល ៧ថ្ងៃ





ប្រើក្រែមពីធម្មជាតិមួយនេះនឹងជួយកម្ចាត់ធាតុកខ្វក់លើផ្ទៃមុខ ហើយផ្ដល់ជាតិសំណើមដល់ស្បែករបស់អ្នក។ អ្នកនឹងមិនចាំបាច់ត្រូវប្រើក្រែមគីមីធ្វើឱ្យស្បែកមុខម៉ត់អ្វីទៀតឡើយ បើសិនអ្នកបានប្រើក្រែមធម្មជាតិនេះរយះពេល ១ សប្ដាហ៏។

**ធាតុផ្សំ**

- ទឹកដោះគោឆៅ
- ប៉េងប៉ោះទុំ។
- ការណែនាំ
- ហាន់ប៉េងប៉ោះជាចំណិតស្ដើងៗ រួចច្របាច់យកគ្រាប់វាចេញឱ្យអស់ ហើយកិនឱ្យម៉ត់លាយក្នុងបរិមាណស្មើគ្នាជាមួយនឹងទឹកដោះគោឆៅ។ ចាក់វាចូលក្នុងដបមួយជាការស្រេច។ ប្រើដុំសំឡីត្រាំក្នុងទឹកនេះ។ បន្ទាប់មកលាបវាលើផ្ទៃមុខរបស់អ្នក និងរង់ចាំរយះពេល១៥នាទី។ អនុវត្តវិធីនេះឱ្យបាន ២ ដងក្នុង១ថ្ងៃ។ លទ្ធផលទទួលបានប្រាកដជាគួរឱ្យភ្ញាក់ផ្អើល។

**ប្រែសម្រួលដោយៈ មង្គលការ**





តមកពីទំព័រទី ០៩

## គណបក្សសង្គ្រោះជាតិរៀនរស់ដោយ...

លោកបានមានប្រសាសន៍ថា "ពីមុនពាក្យស្លោកប្រឆាំងវៀតណាមអាចត្រូវបានចោទប្រកាន់ដោយគណបក្សកាន់អំណាចថា ជាការរើសអើង ប៉ុន្តែ លើកនេះពួកគេអាចចោទប្រកាន់ថា ជាការបង្កើត...ឱ្យមានការញុះញង់"។

នៅមុនការបោះឆ្នោតជាតិឆ្នាំ២០១៣ គណបក្សសង្គ្រោះជាតិកៀងគរបានការគាំទ្រមួយចំនួនតាមរយៈការលើកឡើងអំពីការសង្ស័យដដែលៗថា រដ្ឋាភិបាលមានបំណងកាត់ទឹកដីនៅក្នុងការកំណត់ព្រំដែនជាយូរមកហើយរវាងប្រទេសកម្ពុជា និងវៀតណាម។

បញ្ហានេះជាបញ្ហាដែលគណបក្សប្រជាជនកម្ពុជាមិនចង់ឱ្យមានការលើកឡើងនោះឡើយ។ គណបក្សនេះទំនងជាទទួលស្គាល់ថា ទំនាក់ទំនងជាយូរមកហើយរបស់ខ្លួនជាមួយរដ្ឋាភិបាលក្រុងហាណូយគឺជាហានិភ័យផ្នែកនយោបាយពិតប្រាកដ។ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិបានដឹកនាំអ្នកគាំទ្រពោរពេញទៅដោយកំហឹងជាច្រើនចុះទៅតំបន់ព្រំដែន ហើយបានបញ្ចូលពាក្យពេចន៍រិះគន់ប្រឆាំង "យួន" ឈ្លានពាននិងអន្តោប្រវេសន៍ទៅក្នុងយុទ្ធនាការឃោសនារបស់ខ្លួន។ មជ្ឈដ្ឋានជាច្រើនចាត់ទុកថាពាក្យនេះជាពាក្យប្រើជំនួសឱ្យវៀតណាម ប៉ុន្តែគណបក្សសង្គ្រោះជាតិមិនយល់អ៊ីចឹងទេ។

លោក មាស នី បានថ្លែងថា "គណបក្សសង្គ្រោះជាតិប្រហែលជាត្រូវប្តូរយុទ្ធសាស្ត្ររបស់ខ្លួនដោយមិនត្រូវលើកឡើងពីពាក្យវៀតណាមិចំៗនោះឡើយ ហើយត្រូវពន្យល់ពីគោលនយោបាយដែលអាចដោះស្រាយបញ្ហាជនអន្តោប្រវេសន៍ទូទៅ"។ លោកបានបន្ថែមថា "គ្រាន់តែនិយាយសំដៅដល់ជនអន្តោប្រវេសន៍ទូទៅវាអាច...ធ្វើឱ្យប្រជាពលរដ្ឋដឹងទៅហើយថា នរណាដែលពួកគាត់ចង់សំដៅដល់នោះ។ វិធីនេះជាវិធីដែលគណបក្សប្រជាជនកម្ពុជាពិបាករកហេតុផលមកចោទប្រកាន់ឱ្យគណបក្សប្រឆាំង "ពីបទឃោសនាញុះញង់"។

លោក គល់ បញ្ញា នាយកប្រតិបត្តិគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) បានលើកឡើងថា គណបក្សប្រឆាំងបានបន្ទន់ជំហរក្នុងការនិយាយស្តីរបស់ខ្លួនរួចហើយពាក់ព័ន្ធបញ្ហាព្រំដែនចាប់តាំងពីតំណាងរាស្ត្ររបស់ខ្លួនចំនួនពីររូបត្រូវបានចាប់ខ្លួន និងកាត់ឱ្យជាប់ទោសពីបទចោទប្រកាន់ដូចគ្នាកាលពីពីរឆ្នាំកន្លងមកនេះ ។

ដោយច្បាប់ស្តីពីគណបក្សនយោបាយថ្មីឥឡូវនេះបានចូលជាធរមានហើយនោះ លោកបានមានប្រសាសន៍ថា "ខ្ញុំគិតថា ការប្រើប្រាស់ពាក្យពេចន៍នឹងកាន់តែខ្សោយជាងមុនទៀត"។

លោក គល់ បញ្ញា បានលើកឡើងទៀតថា វាទំនងជាមិនអាចបិទមាត់អ្នកគាំទ្រគណបក្សសង្គ្រោះជាតិភាគច្រើនបាននោះឡើយ ប៉ុន្តែវាអាចធ្វើឱ្យគណបក្សនេះបាត់បង់សំឡេងឆ្នោតពីអ្នកមិនទាន់អាចសម្រេចចិត្តបានដែលនឹងប្រហែលជាងាកទៅបោះឆ្នោតឱ្យគណបក្សផ្សេងជំនួសវិញ ឬក៏មិនបោះឆ្នោតឱ្យគណបក្សណាទាល់តែសោះ។ សំឡេងឆ្នោតទាំងនោះពិតជាមានសារៈសំខាន់នៅតាមបណ្តាខេត្តដែលមានការប្រកួតប្រជែងគ្នាដ៏ស្វិតស្វាញ ហើយរាល់អាសនៈនៅក្នុងសភាដែលមាន១២៣អាសនៈសុទ្ធតែមានតម្លៃ។ បើគណបក្សសង្គ្រោះជាតិទទួលបានត្រឹមតែ៧អាសនៈទៀតនៅក្នុងឆ្នាំ២០១៣ ម្ល៉េះឈ្នះគណបក្សប្រជាជនកម្ពុជាបាត់ទៅហើយ។

លោក គល់ បញ្ញា បានមានប្រសាសន៍ថា "ប្រហែលជាអ្នកបោះឆ្នោតដែលមិនទាន់អាចសម្រេចចិត្តបានមួយចំនួន ពួកគាត់ត្រូវការការយល់ដឹងឱ្យបានកាន់តែស៊ីជម្រៅ"។ លោកបានបន្ថែមថា "ពួកគេឱ្យគណបក្សសង្គ្រោះជាតិ" ចាំបាច់ត្រូវតែចាក់ឱ្យចំបេះដូងរបស់ពួកគាត់ ហេតុដូច្នេះពាក្យពេចន៍សំខាន់ៗ គឺវាមានសារៈសំខាន់ណាស់"។

លោក ឡៅ ម៉ុងហៃ អ្នកវិភាគនយោបាយ និងជាអតីតទីប្រឹក្សាលោក កឹម សុខា នោះ យល់ស្របថា គណបក្សសង្គ្រោះជាតិអាចបាត់បង់សំឡេងឆ្នោតដែលសម្រេចជោគវាសនាមួយចំនួន។

លោកបានមានប្រសាសន៍ថា "វាអាចទៅរួច" ។ លោកបានបន្ថែមថា "ប្រជាពលរដ្ឋចង់បានអ្វីដែលជាក់លាក់ និងចំៗចំណុច"។

ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍របស់គណបក្សសង្គ្រោះជាតិបានលើកឡើងថា គណបក្សនេះចាំបាច់ត្រូវតែណែនាំសមាជិក និងបេក្ខជនរបស់ខ្លួនកុំឱ្យធ្វើការវាយប្រហារដោយផ្ទាល់ខ្លួនដើម្បីអាចបន្តរស់រានទៅមុខទៀត ប៉ុន្តែព្រះអង្គជឿជាក់ថា អ្នកគាំទ្រនឹងនៅតែស្មោះត្រង់ ហើយចូលរួមដដែល "ព្រោះប្រជាពលរដ្ឋចង់បានការផ្លាស់ប្តូរ"។

លោកស្រី មូរ សុខហួរ អនុប្រធានគណបក្សសង្គ្រោះជាតិបានលើកឡើងថា ទោះបីជាគណបក្សរបស់លោកស្រីនិយាយ ឬមិននិយាយក៏ដោយ វាក៏មិនអីដែរ ដោយសារឥឡូវបណ្តាញទំនាក់ទំនងសង្គមបានជួយប្រជាពលរដ្ឋឱ្យយល់ដឹងលែងជឿការឃោសនារបស់រដ្ឋាភិបាល។

ទើបតែប៉ុន្មានថ្ងៃកន្លងមកនេះប៉ុណ្ណោះ លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានលើកឡើងថា ការតែងតាំងលោក កឹម សុខា ជាប្រធានបក្សនៅដើមខែនេះប្រហែលជារំលោភបំពានបទបញ្ជាផ្ទៃក្នុងរបស់គណបក្សនេះ និងធ្វើឱ្យប៉ះពាល់ដល់ឱកាសរបស់គណបក្សសង្គ្រោះជាតិក្នុងការដាក់បេក្ខជនរបស់ខ្លួនសម្រាប់ការបោះឆ្នោតនៅខែមិថុនា។

វាក៏មានការគំរាមពីគណបក្សប្រជាជនកម្ពុជាដាក់ពាក្យបណ្តឹងពីបទញុះញង់ជុំវិញពាក្យស្លោកឃោសនារបស់គណបក្សសង្គ្រោះជាតិ ការបើកការស៊ើបអង្កេតពាក់ព័ន្ធការប្រព្រឹត្តអំពើពុករលួយលើលោក កឹម សុខា ទាក់ទិននឹងការមានស្នេហាលួចលាក់ជាមួយអ្នកធ្វើសក់ម្នាក់ និងការចោទប្រកាន់ការធ្វើកុបកម្មលើមន្ត្រីគណបក្សផ្សេងៗទៀតរបស់គណបក្សនេះពាក់ព័ន្ធការប៉ះទង្គិចគ្នានៅឆ្នាំ២០១៤នៅទីលានប្រជាធិបតេយ្យក្នុងរាជធានីភ្នំពេញផងដែរ។

រដ្ឋាភិបាលអាចចាត់វិធានការទាំងនេះបាននៅពេលណាដែលខ្លួនចង់ ហើយប្រើប្រាស់អំណាចថ្មីរបស់ខ្លួនក្រោមច្បាប់ស្តីពីគណបក្សនយោបាយដើម្បីផ្អាកសកម្មភាពរបស់គណបក្សណាមួយ។ ដោយគណបក្សប្រជាជនកម្ពុជាកាន់តែលែងខ្វាយខ្វល់នឹងការរិះគន់ពីលោកខាងលិចដោយសារមានជំនួយហិរញ្ញវត្ថុកាន់តែច្រើនឡើងៗពីប្រទេសចិននោះ វាជារឿងមួយនឹកស្មានមិនដល់។

ទីបំផុតលោកស្រី មូរ សុខហួរ បានលើកឡើងថា គ្មានអ្វីអាចជួយសង្គ្រោះគណបក្សសង្គ្រោះជាតិពីបំណងយាយីរបស់រដ្ឋាភិបាលដែលមានអំណាចកែប្រែច្បាប់តាមអំពើចិត្តរបស់ខ្លួនបាននោះឡើយ ហើយវាឥតប្រយោជន៍ទេ ទោះជាខិតខំខ្លាំងយ៉ាងណាក៏ដោយ។

លោកស្រីបានមានប្រសាសន៍ថា "ពួកគេអាចបកស្រាយទៅបែបម៉េចក៏បានដែរ។ ប្រសិនបើពួកគេរកវិធីមិនបាននៅថ្ងៃនេះ ក៏ពួកគេអាចរកបានដែរនៅថ្ងៃស្អែក"។ លោកស្រីបានបន្តថា "យើងនឹងធ្វើអ្វីគ្រប់យ៉ាងឱ្យតែផ្តល់ផលប្រយោជន៍ដល់ប្រទេសជាតិ និងប្រជាពលរដ្ឋ"៕

**ស៊ុយឈាង**

Continued from page 11

# OPPOSITION LEARNING TO...

"Maybe some undecided voters, they need some very critical understanding," Mr. Panha said. "They [the CNRP] need to touch their emotions, so critical comments are very important."

Political analyst Lao Mong Hay, a former adviser to Mr. Sokha, agreed that a tamer CNRP could lose some swing votes.

"It's possible," he said. "The people want something specific and straight to the point."

Prince Sisowath Thomico, a member of the CNRP's steering committee, said the party will need to direct its members and candidates away from personal attacks to stay alive, but believed its supporters would stay both loyal and engaged "because the people are starving for change."

CNRP Vice President Mu Sochua said it also mattered less what the party itself does or does not say now that social media is allowing more Cambodians to circumvent the government's propaganda.

But none of the CNRP's restraint will matter if it's not on the ballot.

Only a few days ago, Interior Minister Sar Kheng intimated that Mr. Sokha's appointment as party president earlier this month may have broken the party's own internal rules, jeopardizing the CNRP's chances of fielding any of its candidates come June.

There's also the incitement lawsuit the CPP has threatened to lodge over the CNRP's campaign slogan, the open corruption investigation against Mr. Sokha related to his alleged affair with a hairdresser, and the insurrection charges against other party officials over a 2014 clash at Phnom Penh's Freedom Park.

The government can push ahead with any of them whenever it wants, and use its new powers under the amended party law to suspend the party. With the CPP increasingly willing to suffer the West's rebuke thanks to China's growing financial largesse, it's not unthinkable.

In the end, Ms. Sochua said, no amount of self-censorship can save the CNRP from a government with the power to bend the law to its will, and it was pointless to try too hard.

"They can interpret any way. If they don't find anything today, they can find something tomorrow," she said. "We will do whatever is in the interest of the nation, of the people."


**ដំណឹងលក់ហាងធ្វើក្រចក នៅញូហែមស៊ែរ**

- តុសម្រាប់ធ្វើដៃ ៨
- បន្ទប់បករោម ១
- កៅអីសម្រាប់ធ្វើជើង ៧
- បន្ទប់បោកអ៊ុត ១
- ចង្ក្រានបាយ ១

មានប្រាក់ចំណូល**$300,000**ក្នុងមួយឆ្នាំ

សូមទំនាក់ទំនង Miss. Vivian តាមទូរស័ព្ទលេខ **603-767-3138**

# អតីតអង្គរក្សលោក ហ៊ុន សែន ចាកចោលជួរ ទៅចូលគណបក្សសង្គ្រោះជាតិ

**ដោយខ្មែរផុស ស.រ.អា.**

យុវជនចម្លែកម្នាក់មកពីក្រុងប៉ារីសឈ្មោះ ញ៉ែម ផល្លា ហៅ "DJ ខ្លា"... មានសម្លេងពីរោះ កំពុងច្រៀងបទស្នេហាជាតិនឹងបទរំលឹកស្នាដៃលោក គឹម ឡី នៅគេហដ្ឋានប្រធានយុវជនសង្គ្រោះជាតិនៅឡូវែល សុខផល ប៉ែន កាលពីថ្ងៃទី១៩មិនាកន្លងទៅ, រឹតតែចម្លែកទៀតនៅពេលគេដឹងថា យុវជននោះជាអតីតអង្គរក្សលោកនាយករដ្ឋមន្ត្រីគ្រប់ជំនាន់គឺ ហ៊ុន សែន,... ទើបនឹងសុំសិទ្ធជ្រកកោនបាននៅប្រទេសបារាំង។ យើងបានជួបយុវជននោះ ហើយធ្វើបទសម្ភាសន៍បន្ទាប់ពីដឹងថា យុវជននោះធ្លាប់បានផ្តល់បទសម្ភាសន៍មួយឱ្យវិទ្យុអាស៊ីសេរីពីប្រវត្តិខ្លួននៅក្នុងជួរនៃកងឯកភាពអង្គរក្សដ៏ល្បីល្បាញខាងប្រើដៃក្តៅជាមួយពលរដ្ឋខ្លួនឯងមានទាំងប្រើហឹង្សាលើសមាជិកសភាជាតិទៀតផង តែក៏បានត្រូវអង្គភាពអង្គរក្សនោះ ឆ្លើយបដិសេធថា "មិនដែលមានឈ្មោះ ញ៉ែម ផល្លា នេះ នៅក្នុងអង្គភាពគេទេ"...។

**ខ្មែរផុសស.រ.អា:** អ្នកចូលក្នុងអង្គភាពអង្គរក្សលោក ហ៊ុន សែន តើនៅក្រោមបញ្ជាការលោកឧត្តមសេនីយ ហ៊ីង ប៊ុនហ៊ាង មែនទេ ?

**ញ៉ែម ផល្លា:** -បាទ! ខ្មែរផុសស.រ.អា-ចុះអង្គភាពនោះមានកងកម្លាំងប៉ុន្មាននាក់?

**ញ៉ែម ផល្លា:** -បាទមាន៥,០០០នាក់ នេះបើតាមសម្តីលោកប្រធានកងពលខ្ញុំមិនដែលបាន


ញ៉ែម ផល្លា សុខផល ប៉ែន សង្គ្រោះជាតិ




ឃើញលើក្រដាសទេ!

**ខ្មែរផុសស.រ.អា** -តើលោកចូលបំរើអង្គភាពនោះរបៀបណា?

**ញ៉ែម ផល្លា:** -ខ្ញុំជាសិល្បករចម្រៀងនៅប្រចាំក្រុមភ្លេងមួយ, ថ្ងៃមួយខ្ញុំបានទៅសម្តែងនៅពិធីមួយនាខែត្រឧត្តរមានជ័យក្រុមនាយទាហ៊ានបានឃើញខ្ញុំច្រៀងបានល្អ ក៏ចង់បានខ្ញុំឱ្យចូលក្នុងកងអង្គរក្សសម្តេច ហ៊ុន សែន, ដល់ពេលមកភ្នំពេញវិញ ខ្ញុំក៏ដាក់ពាក្យសុំដូចដែលគេបានណែនាំខ្ញុំ គេក៏ឱ្យខ្ញុំចូលទៅក្នុងក្រុមសម្រាប់ធ្វើការឃោសនា...ចាប់តាំងពីឆ្នាំ២០១០មកម្លេះ...



**ខ្មែរផុសស.រ.អា:** តើការសុំចូលនោះ មានការលំបាកអ្វីដែរទេ? គេមានឆែកប្រវត្តិរូបអីតឹងតែងទេ?

**ញ៉ែម ផល្លា:** -បានឥតលំបាកអីទេ! ហើយក៏គ្មានការឆែកឆេរប្រវត្តិរូបអ្វីទេ...!

**ខ្មែរផុសស.រ.អា** -តើលោកមានតួនាទីអ្វីនៅក្នុងអង្គភាពអង្គរក្សនោះ? តើធ្វើអ្វីខ្លះទៅ?

**ញ៉ែម ផល្លា:** ខ្ញុំចូលទៅធ្វើការក្នុងក្រុមអង្គរក្សនៅឆ្នាំ២០១០ ខ្ញុំមានឋានន្តរស័ក្តិជាសក្តិ៣ នៅក្នុងអង្គភាពពតិមាននឹងឃោសនា ខ្ញុំតែងដើរទៅច្រៀងនៅគ្រប់កន្លែងណាដែលមានការឃោសនាឱ្យគណបក្សប្រជាជនម្តង១ ដើម្បីកំដរនឹងកំសាន្តប្រជាពលរដ្ឋព្រមទាំងពលទាហ៊ានក្នុងពិធីនានា... ធ្វើការរហូតដល់ឆ្នាំ២០១៣ទើបខ្ញុំសុំលាលែង... អង្គភាពអង្គរក្សនោះ មានចែកជាច្រើនក្រុម ក្រុមយើងជាអ្នកប្រគុំតន្ត្រីសម្រាប់តែធ្វើការឃោសនាតែប៉ុណ្ណោះ...

**ខ្មែរផុសស.រ.អា** -តើលោកមានដែលទទួលបញ្ជាឱ្យទៅបង្ក្រាបបាតុករណាម្តងទេ ?

**ញ៉ែម ផល្លា:** -អត់ដែលទេ!

**ខ្មែរផុសស.រ.អា** -ចុះមានដែល ដឹងថាក្នុងអង្គភាពអង្គរក្សលោក ហ៊ុន សែន មានអង្គភាពមួយជាអ្នកដៃដល់មិនត្រឹមតែការពារសុវត្ថិភាពលោកនាយករដ្ឋមន្ត្រីតែប៉ុណ្ណោះទេ តែសម្រាប់គេប្រើទៅបង្ក្រាបបាតុករណាដែលប្រឆាំងរដ្ឋាភិបាលទៀត មានដែរឬទេ?

**ញ៉ែម ផល្លា:** -ខ្ញុំមិនបានដឹងដល់រឿងយ៉ាងនេះទេ

**ខ្មែរផុសស.រ.អា** -បើដូច្នោះមានស្គាល់មុខសមាជិកកងអង្គរក្សប៉ុន្មាននាក់ដែលអ្នកកាសែតបានបង្ហាញមុខថាបានវាយតប់បាតុករ ឬក៏វាយតប់លើអ្នកតំណាងរាស្ត្រ ដែរឬទេ?

**ញ៉ែម ផល្លា:** -បាទមិនស្គាល់ទេ គ្រាន់តែប្រហែលមុខ...តែបើពេលគេបង្ហាញក្នុងឯកសណ្ឋានទាហ៊ាន នោះគឺជាឯកសណ្ឋានកងអង្គរក្សនោះហើយ!

**ខ្មែរផុសស.រ.អា** -តើគេមានឱ្យលោក ធ្វើសច្ចាប្រណិធានឱ្យស្មោះត្រង់ នឹងមានភក្តីភាពប្តូរផ្តាច់ចំពោះលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែរឬទេ?

ញ៉ែម ផល្លា: -បាទ ឥតមានទេ!

**ខ្មែរផុសស.រ.អា** ហេតុអ្វីបានជាលោកចាកចេញពីអង្គភាពអង្គរក្សលោក ហ៊ុន សែន?

**ញ៉ែម ផល្លា:** បាទខ្ញុំដឹងថា កងអង្គរក្សដែលខ្ញុំធ្វើការជាមួយបានធ្វើអំពើអយុត្តិធម៌មួយចំនួនលើប្រជាពលរដ្ឋ, តែក៏បានធ្វើមកលើគ្រួសារខ្ញុំដែរ ដែលខ្ញុំចង់រកយុត្តិធម៌ឱ្យគ្រួសារខ្ញុំតាមតុលាការ តែអង្គភាពខ្ញុំមិនព្រមឱ្យខ្ញុំធ្វើទេ ពីព្រោះវានាំឱ្យខូចឈ្មោះអាសោចន៍ដល់អង្គភាព, ខ្ញុំក៏សុំលាលែងចេញពីអង្គភាពតែគ្មាននរណាអនុញ្ញាតិឱ្យខ្ញុំចេញបានទេ, ខ្ញុំបានឡើងទៅដល់លោកឧត្តមសេនីយឯក ហ៊ីង ប៊ុនហ៊ាង តែលោកច្រានឱ្យទៅឱ្យអ្នកបន្ទាប់ជាអ្នកដោះស្រាយ រីឯអ្នកបន្ទាប់ក៏ញ៉េបន្តទៅអ្នកផ្សេងអស់ពេលច្រើនខែ ទើបបានជួបឧត្តមសេនីយត្រីម្នាក់យល់ព្រម"ស៊ីញ៉េ"ទទួលពាក្យសុំលារបស់ខ្ញុំ១ក៏ចាកចេញពីអង្គភាពតែម្តង!

**ខ្មែរផុសស.រ.អា** -តើចេញពីអង្គភាពមួយនេះ អាចមានគ្រោះថ្នាក់ដល់ខ្លួនដែរឬទេ?

**ញ៉ែម ផល្លា:** -ដោយសារតែសភាពការគ្រោះថ្នាក់នេះហើយ ទើបខ្ញុំគេចខ្លួន! មិនជាការស្រួលទេ មានគេតាមរកខ្ញុំដល់ផ្ទះ តែខ្ញុំបានគេចខ្លួន ពីព្រោះដឹងខ្លួនថានឹងមានគ្រោះថ្នាក់ធ្ងន់ធ្ងរហើយក៏គ្មាននរណាអាចជួយការពារខ្ញុំបានទេ!

**ខ្មែរផុសស.រ.អា** -ហើយធ្វើដូចម្តេចទើបបានចេញទៅដល់ស្រុកបារាំង?

**ញ៉ែម ផល្លា:** -បាទបានក្រុមការពារសិទ្ធិមនុស្ស គេដឹងរឿង ក៏ជួយរកផ្លូវឱ្យខ្ញុំចេញមកក្រៅ ហើយខាងបារាំងគេទទួលយកខ្ញុំចេញមកភ្លាម ។

**ខ្មែរផុសស.រ.អា** -ឥឡូវបានសុខហើយ តើមាននាំគ្រួសារមកទាំងអស់គ្នាទេ?

**ញ៉ែម ផល្លា:** -មិនទាន់ចប់សព្វគ្រប់ទេ ពីព្រោះគេតាមរករឿងប្រពន្ធខ្ញុំទៀត, ប្រពន្ធខ្ញុំកំពុងរស់នៅក្នុងសភាពលាក់ខ្លួន...ឥឡូវគេចចេញបានមកដល់ប្រទេសក្រៅហើយ តែខ្ញុំមិនអាចនិយាយថា **តទៅទំព័រទី ១៨**

តមកពីទំព័រទី ១២
## នាយករដ្ឋមន្ត្រីថា តំណែងយ៉ាងច្រើនរបស់លោក...

ជារដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រីបានប្រកាសលឿនស្លេវនូវសេចក្តីសម្រេចដែលថ្នាក់លើរបស់លោកមិនទាន់ទាំងបានព្រមព្រៀងផង។ លោកថ្លែងថា "មេមិនទាន់ស៊ីសងផង ចេញរួចហើយ" ហើយថា លោក ផៃ ស៊ីផាន នឹងមិនប្រឈមការដាក់ពិន័យទេ ប៉ុន្តែត្រូវយកប្រសាសន៍របស់នាយករដ្ឋមន្ត្រីធ្វើជាថ្នាំព្យាបាល ដើម្បីកុំឱ្យថ្ងៃក្រោយធ្វើខុសបែបនេះទៀត។ លោកមានប្រសាសន៍ថា "ឥឡូវដើម្បីកែចាក់មួយម្ជុលឱ្យបាត់ឆ្កួត"។

នៅពេលស្តីបន្ទោសរួចហើយ លោក ហ៊ុន សែន បានបង្ហាញពីវិធីបែងចែកមុខតំណែងផ្សេងៗរបស់លោក សុខ អាន ឱ្យទៅក្រសួងមួយចំនួន។

ទាំងអាជ្ញាធរអប្សរាដែលគ្រប់គ្រងឧទ្យានបុរាណអង្គរ និងអាជ្ញាធរគ្រប់គ្រងប្រាសាទព្រះវិហារ ដែលជាតំបន់ទេសចរណ៍ដ៏មានតម្លៃបំផុតមួយទៀតរបស់កម្ពុជា នឹងត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់លោកស្រី ភឿង សកុណា ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងវប្បធម៌។ លោកស្រីក៏នឹងកាន់តំណែងរបស់លោក សុខ អាន ជាប្រធានគណៈកម្មការជាតិយូណេស្កូផងដែរ។

សមាគមជាតិកាយឫទ្ធិកម្ពុជា ជាក្រុមយុវជនមួយដែលមជ្ឈដ្ឋានទូទៅចាត់ទុកជាក្រុមជ្រើសរើសកម្លាំងសម្រាប់គាំទ្រគណបក្សកាន់អំណាចនឹងស្ថិតក្រោមការគ្រប់គ្រងរបស់លោក ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ។ ពេលនេះគណៈកម្មាធិការផ្លូវដែកនឹងត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់លោក ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ចំណែកឯក្រុមប្រឹក្សាវិស្វកម្មនឹងត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ។

លោក ប៊ិន ឈិន នឹងកាន់តំណែងរបស់លោក សុខ អាន ជាប្រធានខាងភាគីជាតិនៃសាលាក្តីខ្មែរក្រហម ជាតំណែងបោកបញ្ឆោតមួយដែលតម្រូវឱ្យរក្សាទំនាក់ទំនងដ៏រសើបជាមួយអង្គការសហប្រជាជាតិដែលគ្រប់គ្រងខាងភាគីអន្តរជាតិនៃតុលាការនេះ និងដែលចង់ឱ្យបន្តសំណុំរឿងប្រឆាំងរដ្ឋាភិបាល។

លោកក៏នឹងទទួលតំណែងកិត្តិយសជាប្រធានរាជបណ្ឌិតសភាកម្ពុជាជាស្ថាប័នសិក្សាស្រាវជ្រាវជាន់ខ្ពស់របស់រដ្ឋនិងគ្រប់គ្រងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលផងដែរ។

មុខតំណែងភាគច្រើនរបស់លោក សុខ អាន ជាពិសេសបំផុតអាជ្ញាធរប្រេងកាតជាតិកម្ពុជា ត្រូវបានដកពីការគ្រប់គ្រងផ្ទាល់របស់លោកប្រគល់ឱ្យទៅក្រសួងរ៉ែ និងថាមពល។ ស្ថាប័នរដ្ឋជាង១០ទៀតត្រូវបានដកពីការគ្រប់គ្រងរបស់លោក សុខ អាន នៅឆ្នាំ២០១៣ បន្ទាប់ពីគណបក្សកាន់អំណាចមានការភ្ញាក់ផ្អើលចំពោះជ័យជម្នះយ៉ាងប្រកៀកប្រកិតគ្នានៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលមជ្ឈដ្ឋានជាច្រើនចាត់ទុកថាជាចំណាត់ការមួយដើម្បីចែកគ្នាមានបានក្នុងជួរគណបក្សកាន់អំណាច។

លោក ផៃ ស៊ីផាន បានលើកឡើងនៅពេលនោះ និងជាថ្មីម្តងទៀតកាលពីម្សិលមិញថាមូលហេតុដែលលោក សុខ អាន គ្រប់គ្រងស្ថាប័នច្រើនសន្ធឹកសន្ធាប់បែបនេះតែម្នាក់ឯងដោយសារភាពចាំបាច់ពីព្រោះកាលពីមុនក្រសួងជាច្រើនខ្វះសមត្ថភាពគ្រប់គ្រងស្ថាប័នរដ្ឋសំខាន់ៗ ជាស្ថានភាពមួយដែលលោកថ្លែងថា បានផ្លាស់ប្តូរក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ។

លោកពន្យល់ពីមូលហេតុដែលលោក សុខ អាន មន្ត្រីកំពូលរបស់លោកនាយករដ្ឋមន្ត្រីកាន់មុខតំណែងយ៉ាងច្រើនថា "កាលណោះយើងត្រូវការបែបនោះ។ ពេលនេះក្រសួងមានសមត្ថភាពគ្រប់គ្រាន់អាចដោះស្រាយរឿងនោះដោយខ្លួនឯងបានហើយ"។

ទាក់ទិនការស្តីបន្ទោសពីសំណាក់លោកនាយករដ្ឋមន្ត្រីលោក ផៃ ស៊ីផាន បញ្ជាក់ថា លោកមិនអាម៉ាស់ទេ ប៉ុន្តែផ្ទុយទៅវិញលោកមានតែអរគុណចំពោះដំបូន្មាននេះ។

អ្នកនាំពាក្យរូបនេះថ្លែងថា "ខ្ញុំគោរពការដឹកនាំរបស់សម្តេចខ្ញុំអរគុណសម្តេច"។ លោកបន្ថែមថា តាមពិតលោកមានបំណងចង់ជូនដំណឹងដល់ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយនានាថា លោក ប៊ិន ឈិន ទទួលកាន់មុខតំណែងរបស់លោក សុខ អាន ជាបណ្តោះអាសន្ន ខណៈលោក ហ៊ុន សែន សម្រេចលើផែនការរយៈពេលវែង។

លោកបានលើកឡើងថា លោក ហ៊ុន សែន "មានអធិបតេយ្យភាពក្នុងការផ្ទេរការទទួលខុសត្រូវឱ្យទៅស្ថាប័នណាមួយ។ នេះជាវិមជ្ឈការ"៕ **សុខុម**

Continued from page 12
## SOK AN'S FIEFDOM TO BE SPLIT UP...

and the authority overseeing the PreahVihear temple-another of the country's most prized tourist attractions-will be overseen by PhoeungSakona in her capacity as the Culture Minister. She will also take SokAn's position as head of the National Commission for Unesco.

The National Association of Cambodian Scouts, a youth group widely seen as a recruitment arm for the ruling party, will move under the purview of Education Minister Hang Chuon Naron. The country's railway committee will now be controlled by the transport minister, Sun Chanthol, while the engineering council will be moved to the Labor Ministry.

Mr. Chhin will take on SokAn's position as the government's point man for the Khmer Rouge tribunal, a tricky position that requires maintaining sensitive relations with the U.N., which controls the international side of the court and would like to see government-opposed cases move ahead.

He will also take on the largely honorary position of president of the Royal Academy of Cambodia, ostensibly the state's bastion of higher-level scholarship and research, and oversee the State Secretariat of Civil Aviation.

Much of SokAn's portfolio, most notably the Cambodian National Petroleum Authority, had already been shifted from his direct control to the ministry most capable of absorbing the body-in the case of the petroleum agency, the Mines and Energy Ministry. More than a dozen state bodies were moved from SokAn's control in 2013, after the ruling party was shaken by a narrow victory in the national election, in what many saw as a move to spread wealth within the ruling party.

Mr. Siphan said at that time and again on Wednesday that Sok An wielded such broad control as a matter of necessity because many ministries previously lacked the capacity to control important state bodies, a situation that he said had changed over the years.

"At that time, we needed that," he said on Wednesday, explaining why Sok An, the prime minister's top lieutenant, took on so many jobs. "This time, the ministries have enough ability to deal with that themselves."

Regarding his dressing-down by the prime minister, Mr. Siphan said he was not embarrassed, but rather grateful for the advice.

"I respect his leadership. I feel thankful to him," the spokesman said, adding that he had actually intended to inform media outlets that Mr. Chhin would temporarily take on SokAn's portfolio while Mr. Hun Sen decided on a long-term plan.

Mr. Hun Sen "has the sovereignty to delegate responsibility to any institution," Mr. Siphan said. “This is decentralization”.

តមកពីទំព័រទី ១០
## រដ្ឋាភិបាលចាត់ទុកតួនាទីរបស់...

គណបក្សនេះបានបដិសេធ។

ការវាយប្រហាររបស់រដ្ឋាភិបាលទៅលើដំណើរការផ្ទៃក្នុងរបស់គណបក្សប្រឆាំងអាចមានផលប៉ះពាល់ខ្លាំង។

យោងតាមលោកស្រី មូរ សុខហួរ តំណាងរាស្ត្រ និងជាអនុប្រធានមួយរូបក្នុងចំណោមអនុប្រធានជ្រើសរើសថ្មីទាំងនោះបានឱ្យដឹងថា គណបក្សប្រញាប់ប្រញាល់តែងតាំងលោក កឹម សុខា និងអនុប្រធាន៣រូបកាលពីដើមខែនេះ ពីព្រោះច្បាប់ស្តីពីគណបក្សនយោបាយតម្រូវឱ្យមានប្រធានអចិន្ត្រៃយ៍មួយរូបដើម្បីអនុម័តយល់ព្រមលើបេក្ខភាពក្រុមប្រឹក្សាឃុំសង្កាត់ដែលគ្រោងដាក់ជូនឈ្មោះទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅចុងសប្តាហ៍ទី១នៃខែនោះ។

លោក ឆាំ ប៊ុនថេត អ្នកវិភាគនយោបាយដែលជឿថា តួនាទីរបស់គណបក្សប្រឆាំងក្នុងការបោះឆ្នោត ឃុំ សង្កាត់នៅខែមិថុនា អាចជួបវាសនាអាក្រក់តាមវិធីមួយ ឬវិធីផ្សេងទៀត នោះបានមានប្រសាសន៍ថា ប្រសិនបើរដ្ឋាភិបាលចាត់ទុកតួនាទីប្រធានរបស់លោក កឹម សុខា ថា មិនស្របតាមច្បាប់ នោះការដាក់ជូនបេក្ខភាពទាំងនោះអាចគ្មានសុពលភាព។




President Kem Sokha speaks to party officials during a meeting in Preah Sihanouk province in January, in a photograph posted to his Facebook page.

លោកបានថ្លែងថា "ប្រសិនបើគណបក្សប្រជាជនកម្ពុជាអនុញ្ញាតឱ្យគណបក្សសង្គ្រោះជាតិចូលរួមនៅក្នុងការបោះឆ្នោតនេះ នោះពួកគេអាចបាត់បង់អំណាចពាក់កណ្តាលនៅថ្នាក់មូលដ្ឋាន"។ លោកបានបន្ថែមថា គណបក្សកាន់អំណាចអាចអញ្ជើញគណបក្សប្រឆាំងឱ្យមកកាន់តុចរចាវិញ ដើម្បីធ្វើឱ្យការរិះគន់ពីសំណាក់អន្តរជាតិស្ងប់ស្ងាត់បន្ទាប់ពីការបោះឆ្នោត។

លោកបានបន្ថែមទៀតថា "វាជាហ្គេមដ៏ឆ្លាតឆ្លាតខាងអាក្រក់។ នយោបាយនៅក្នុងប្រទេសនេះ គឺគេលេងបែបនេះ"៕

សារុន (រាយការណ៍បន្ថែមដោយ Ben Paviour)

# iPhone 7
# ពណ៌ក្រហមមានលើទីផ្សារ

ក្រុមហ៊ុន Apple កាលពីថ្ងៃទី២១ ខែមិនា បានប្រកាសនូវផលិតផលថ្មីពិសេសរបស់ខ្លួន គឺ ិPhone 7nigiPhone 7 Plus ដែលមានពិណក្រហម នៅលើទីផ្សារ។ សម្រាប់ផលិតផលថ្មីនេះ អតិថិជន តង់ហ្សានី និងសំបីដែលជាទីកន្លែងមានអ្នកផ្ទុកមេរោគអេដធំបំផុតលំដាប់ទី២ ក្នុងពិភពលោក។

អស់រយៈពេល១០ឆ្នាំ មកហើយដែល Apple និង (RED) បានការសហការគ្នាដើម្បី




បានចាប់ផ្តើមបញ្ជាទិញផ្ទាល់ទូទាំងពិភពលោក និងមានការដាក់លក់នៅលើទីផ្សារចាប់ពីថ្ងៃសុក្រទី២៤ ខែមីនា។

អ្វីដែលគួរកត់សម្គាល់នោះគឺថា ផលិតផលនេះ កើតចេញពីការសហការគ្នារវាងក្រុមហ៊ុន Apple និងក្រុមហ៊ុន (RED) ហើយវាជាយុទ្ធនាការថ្មីមួយក្នុងគោលបំណងដើម្បីប្រមូលថវិការជួយដល់អង្គការ Global Fund ក្នុងការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលជំងឺអេដនៅអនុតំបន់សាហារ៉ាទ្វីបអាហ្វ្រិកដូចជាប្រទេសហ្កាណា, លីសូធូ, រ៉ាន់ដា, អាហ្វិចខាងត្បូង, កែនយ៉ា, ជួយដល់អង្គការ Global Fund ក្នុងនោះគឺ Apple ជាអ្នកឧបត្ថម្ភធំជាងគេបំផុតរបស់ពិភពលោកដោយបានផ្តល់ជំនួយជាទឹកប្រាក់១៣០ លានដុល្លារ ហើយថវិការនេះក៏មានចំណែករបស់ក្រុមហ៊ុន(RED)ផងដែរ។ ដូច្នេះរាល់ការជាវទូរស័ព្ទស្មាតហ្វូនប្រភេទ (PRODUCT)RED iPhone នេះគឺជាការរួមចំណែកថវិការមួយដល់អង្គការ Global Fund ក្នុងការទប់ស្កាត់ការឆ្លងជំងឺអេដ ជាពិសេសគឺពីម្តាយទៅទារកក្នុងតំបន់អាហ្វ្រិក៕

**រៀបរៀងដោយខ្មែរផុសស.រ.អា**

តមកទំព័រទី ១៦ អតីតអង្គរក្សលោក ហ៊ុន សែន...

នៅទីណាបាននៅឡើយទេ ពីព្រោះគេអាចមានគ្នាទៅចាប់នាំមកស្រុកខ្មែរវិញបាន...

**ខ្មែរផុសស.រ.អា.** -លោកចេញមកដោយស្ងៀមស្ងាត់ទេ តែគ្រោះថ្នាក់នៅតែមាន, តើអ្វីទៅដែលធ្វើឱ្យអង្គភាពអង្គរក្សនោះនៅតែតាមរករឿងលោក ?

**ពៀម ផល្លា:** - ប្រហែលជាគេមិនសប្បាយចិត្តនឹងខ្ញុំនិយាយនៅ"អាស៊ីសេរី" ហើយគេដឹងថាខ្ញុំនៅជាមួយគណបក្សសង្គ្រោះជាតិទៀត...តាមពិតទៅខ្ញុំមានការពេញចិត្តនឹងគណបក្សសង្គ្រោះជាតិនេះយូរហើយ...

**ខ្មែរផុសស.រ.អា** - តើនៅក្នុងអង្គភាពអង្គរក្សលោក ហ៊ុន សែន នោះមានអ្នកចូលចិត្តគណបក្សសង្គ្រោះជាតិច្រើនទេ?

**ពៀម ផល្លា:** -បាទខ្ញុំមិនបានដឹងទេ ពីព្រោះមិនដែលនរណាហ៊ាននិយាយចេញមកទេ!

**ខ្មែរផុសស.រ.អា.** -លោកនៅស្រុកបារាំងតើនៅម្តុំកន្លែងណា?

**ពៀម ផល្លា:** - បាទនៅ "ប៉ារីស" តែម្តងនៅតំបន់លេខ៧៧

**ខ្មែរផុសស.រ.អា.** តើនៅសហរដ្ឋនេះបានប៉ុន្មានថ្ងៃ?

**ពៀម ផល្លា:** បាទ ! នៅរហូតដល់ចូលឆ្នាំហើយ ។

**ខ្មែរផុសស.រ.អា.** សូមអរគុណ ! ៕













## តមកទំព័រទី ០៤ សមាគមអង្គរប្រារព្ធខួបអាយុ៣០ឆ្នាំ...

ដែលចេញទៅមានគ្រួសារ ឬទៅធ្វើការឆ្ងាយៗមានប្រហែល៥០នាក់ដែលបានចេញទៅ ហើយតែនៅតែមកហាត់ហ្វឹកហ្វឺនខ្លួនដែលអាចឱ្យយើងរាប់បានថា ជា"ក្រុមស្នូល" ដែលយើងអាចប្រើការបានសម្រាប់តម្លើងជាឆាកជាទស្សនីយភាពធំៗបាន ។

លោក ធឹម ធូ បានបន្តថា ថ្វីត្បិតតែយើងមានក្រុមមួយដ៏ជំនាញក្នុងវិស័យសិល្បៈនឹងវប្បធម៌ខ្មែរហើយក៏ដោយ ក៏យើងនៅមិនទាន់បង្កើតបានជាសាលាបង្ហាត់ដូចជាស្ថាប័នមួយនៅឡើយទេ ដោយយើងមិនអាចមានសមត្ថភាពរក្សាគ្រូបង្ហាត់ពេញម៉ោងតែម្នាក់ក៏មិនទាន់បាននៅឡើយផង ដូច្នេះនៅតែមិនអាច"ស្ល"សិស្សឱ្យទៅជា"គ្រូ"បានពេញលក្ខណៈដូចនៅសាកលវិទ្យាល័យវិចិត្រសិល្បៈ ឯភ្នំពេញបានទេ ។ ម្យ៉ាងវិញទៀតទស្សនីយភាពធំៗដែលបានចេញសម្តែង២-៣ឆ្នាំចុងក្រោយនេះ ដូចជារឿង "ពិណបញ្ចពណ៌" ជាដើម មានទំហំនឹងបច្ចេកទេស ក៏វីត "វិជ្ជាជីវៈ" បានហើយ នេះបើយោងតាមការឱ្យយោបល់នានារបស់សាធារណជនដែលធ្វើឱ្យយើងមានមោទនភាពចំពោះគ្រូនឹងសិស្សរបស់យើងខ្លាំងណាស់ តែនឹកទៅដល់គម្រោងរៀបចំឱ្យទៅជាក្រុមវិជ្ជាជីវៈនោះ មិនទាន់ហ៊ាននឹកទៅដល់នោះទេ ពីព្រោះត្រូវការធនធានច្រើន នឹងការស្គាល់ទីផ្សារសិល្បៈខ្មែរឱ្យធំទូលាយទៀត ដែលមិនអាចឱ្យយើងគិតដល់នៅឡើយ ។

សមាគមអង្គរបើទោះជាកំពុងល្បីល្បាញទៅហើយក៏ដោយ ក៏នៅតែចង់បានការគាំទ្រពីសហគមន៍ខ្មែរឱ្យបានច្រើនជាងនេះ ដោយការសម្តែងមតិដោយបញ្ជូនកូនចៅឱ្យមកសិក្សារបាំជាវប្បធម៌ខ្មែរ ឬក៏ជួយជាវិភាគទាន ដើម្បីបង្កើនសមត្ថភាពសមាគមឱ្យការបង្ហាត់បង្រៀនមានភាពទូលំទូលាយជាងសព្វថ្ងៃនេះបាន ៕

## តមកទំព័រទី ០៣ បុណ្យផ្កាប្រាក់"វត្តខ្មែរសាមគ្គីសន្តិការាម

សែម សារិន, គណកម្មការវត្តនឹងពុទ្ធបរិស័ទជើងវត្តត្រូវរកប្រាក់សងរំលោះវិនិយោគចាស់ជាង២០០០ក្នុងមួយខែ ជារៀងរាល់ខែបន្តទៅទៀត រហូតដល់រំលោះចប់ ។

វត្តសាមគ្គីសន្តិការាមមានព្រះសង្ឃគង់ជាប្រចាំចំនួន៤អង្គ សម្រាប់ជាទីពឹងពាក់ក្នុងការប្រារព្ធពិធីតាមទំនៀមទំលាប់ព្រះពុទ្ធសាសនាខ្មែរជូនប្រជាពលរដ្ឋខ្មែរដ៏ច្រើនដែលមករស់នៅក្នុងតំបន់, តែក៏មានប្រជាពលរដ្ឋឡាវ នឹងថៃ ឥឡូវមានភូមាទៀត ដែលកាន់សាសនាដូចគ្នាក៏មករកវត្តអារាមខ្មែរដូចប្រជាពលរដ្ឋខ្មែរដែរ ៕






# ទូរស័ព្ទ Galaxy S8 ជំនាន់ក្រោយរបស់ Samsung ចេញចុងខែនេះហើយ



បន្ទាប់ពីក្រុមហ៊ុនដ៏ធំជាងរបស់កូរ៉េខាងត្បូង Samsung បានសូមទោសដល់អ្នកប្រើប្រាស់របស់ខ្លួនចំពោះបញ្ហាលើដំណើរការថ្មរបស់ Samsung GalaxyNote 7 កាលពីឆ្នាំមុននោះ ដែលបានធ្វើឱ្យក្រុមហ៊ុនបង់ខាតប្រាក់រាប់លានដុល្លារឥឡូវនេះក្រុមហ៊ុនបាននឹងកំពុងរចនានូវស្មាតហ្វូនជំនាន់ក្រោយរបស់ខ្លួន គឺ GalaxyS8nig Galaxy S8+ ដោយសង្ឃឹមថា នឹងអាចធ្វើឱ្យក្រុមហ៊ុនស្រូបបានប្រាក់ចំណេញមកវិញ។

កាលពីពេលថ្មីៗមានព័ត៌មានជាច្រើននៅតាមប្រព័ន្ធអ៊ីនធរណេតទាក់ទងនឹង Samsung GalaxyS8 ជាពិសេសពណ៌, រូបរាង និងតំលៃរបស់វា។ បើតាមពណ៌របស់ GalaxyS8 ដែលនឹងបង្ហាញខ្លួនគឺពណ៌ខ្មៅ, ប្រផេះ និងពណ៌ប្រាក់។ ចំណែករូបរាងគឺមានផ្ទៃកញ្ចក់រាងកោងនៅគែម និងជ្រុងសងខាងមានរាងកោង។ ជាមួយគ្នានេះដែរ អ្នកប្រើប្រាស់ប្រហែលមិនឃើញមាននូវប៊ូតុង Home របស់ស្មាតហ្វូនជំនាន់ក្រោយនេះទេ តែអាចឃើញការនាំយកមកនូវមុខងារសមត្ថភាពក្នុងការដោះសោរដោយប្រើប្រាស់ក្រយៅម្រាមដៃ (Fingerprint Sensor) និងមាន back button នៅខាងស្តាំ ។

អេក្រង់របស់ GalaxyS8+ មានទំហំ 6.2-inch Quad HD+ Super AMOLED ចំណែកឯ GalaxyS8 មានអេក្រង់ទំហំ 5.8-inch. ស្មាតហ្វូនទាំងពីរមានទំហំ Ram4G និង Memory 64GB ហើយមានកាម៉ារាទំហំ 12-megapixel Dual Pixel ។ ទាំងពីរម៉ូដែលនេះគឺដំណើរការដោយប្រព័ន្ធ Qualcomm Snapdragon 835 ថ្មីរបស់ Samsung. អ្វីដែលពិសេសនោះគឺថា ក្រុមហ៊ុននឹងដាក់ឱ្យប្រើប្រាស់នូវកម្មវិធី Bixby ដែលមានលក្ខណៈខុសគ្នាពីកម្មវិធី Siri ឬ Cortana ។ នៅពេលពេលដែលយើងចង់បញ្ជា ឬធ្វើអ្វីមួយនៅក្នុងទូរស័ព្ទស្មាតហ្វូន ចាំបាច់ត្រូវតែប្រើ touch command តែកម្មវីធី Bixby វាភាពងាយស្រួលដល់អ្នកប្រើប្រាស់ដោយគ្រាន់តែប្រើសម្លេង (Voice command) ជាការស្រេច និងមានមុខងារជាច្រើនទៀត ដោយគ្រាន់តែភ្ជាប់ជាមួយ Internet និង microphone។ បើយោងតាមថ្វីតធ័ររបស់លោក អ៊ីវ៉ិន ប្លស បានឱ្យដឹងថា GalaxyS8 មានតំលៃប្រហែល៨៥៩ដុល្លារ និង GalaxyS8+ តំលៃ ៩៥៩ដុល្លារអាមេរិក។

បើតាមប្រភពវិបសាយរបស់ក្រុមហ៊ុនបានឱ្យដឹងថា Samsung គ្រោងនឹងបង្ហាញនូវផលិតផល GalaxyS8 ជំនាន់ក្រោយជាផ្លូវការនៅថ្ងៃទី ២៩ ខែមីនានេះ ក្នុងកម្មវីធី Galaxy Samsung Unpacked Event ទីក្រុង New York។ ប៉ុន្តែនៅមិនទាន់ប្រកាស់ឱ្យដឹងពីការចេញលក់ជាផ្លូវការនៅលើទីផ្សារនោះទេ។ តែបើតាមប្រភពក្រៅផ្លូវការក្រុមហ៊ុន Samsung នឹងចេញលក់នៅលើទីផ្សារពិភពលោកនៅថ្ងៃទី ២៨ខែមេសា។ ជាមួយគ្នានេះដែរនៅមិនទាន់មានព័ត៌មានពីកាលបរិច្ឆេទផ្លូវការនៃការបើកទទួលការកក់នៅឡើយនោះទេជាពិសេសនៅអាមេរិក តែនៅអង់គ្លេសមានព័ត៌មានទទួលកក់មុនសម្រាប់ស្មាត់ហ្វូនទាំងពីរម៉ូដែលនេះហើយ។ យើងរង់ចាំតាមដានព័ត៌មានជាក់លាក់ទាំងអស់គ្នានៅថ្ងៃប្រកាសចុងខែនេះ៕



**រៀបរៀងដោយ សុខារ័ត្ន កួយ**




# តម្រឹមធ្មេញដោយមិនយកថ្លៃ

ប្រសិនបើលោកអ្នកឬគ្រួសារ មានអាយុ២១ឆ្នាំ ឬក្មេងជាង សូមទូរស័ព្ទមកយើងនៅថ្ងៃនេះ ដើម្បីរកមើលថាតើលោកអ្នកមានសិទ្ធនឹងទទួលបាននូវ "ប្រដាប់តម្រឹមធ្មេញ"ដោយ មិនចំណាយប្រាក់ ឬទេនៅពេលលោកអ្នកមាន"ម៉ាសហ៊ែល"? លោកអ្នកអាចនឹងទទួលសំណងរហូតដល់៤,៣០០ដុល្លា សម្រាប់ដាក់"ប្រដាប់តម្រឹមធ្មេញ"ទៅតាមសេចក្ដីត្រូវការរបស់អ្នក។

The BRACES PLACE

វេជ្ជបណ្ឌិត មូហាប់ រីសកាឡា DDS MSD

## តើយើងធ្វើអ្វីខ្លះ?

ដាក់ធ្មេញដោយដែក * ដោយមាស * ដោយ"អិនវីសាឡាញ" * ដោយចាន

## អ្វីដែលធ្វើឱ្យយើងប្រសើរជាងនោះ?

- ឆ្លុះមើលបន្ថែម នឹង ជួបគ្រូពេទ្យ
- យើងទទួលយក"ម៉ាសហ៊ែល" នឹង "អិនស្ទូរិន"ផ្សេងៗទៀត
- បង់ប្រាក់កក់មុនតិចបំផុត នឹងមានវិធីបង់ប្រាក់រំលោះប្រចាំខែសម្រាប់អ្នកដែលគ្មាន"អិនស្ទូរិន" សូមទូរស័ព្ទ ឬក៏មកកន្លែងដែលស្រួលរករបស់យើង

710 Chelmsford St. Lowell, MA 01851
**(978)- 454 - 0774** (មានអ្នកនិយាយភាសាខ្មែរ)
ដើម្បីបានព័ត៌មានបន្ថែម, សូមចូលទៅ"វេបសាយ"យើង: www.bracesplaces.com

តមកពីទំព័រទី ០៦

# វិទ្យាល័យ"ឡូវិហាយស្គូល" ត្រូវរៀបចំ

សំណើរដំបូងចំនួន៧៥កន្លែង ឥឡូវនៅសល់ក្នុងបញ្ជីសំណើរតែ៤កន្លែងទេ មាន៣កន្លែងនៅក្នុងកណ្តាលក្រុងនឹង១កន្លែងនៅក្រៅក្រុង, ដែលសហគមន៍"ខ្មែរ"នឹង"ស្បានីស"បានត្រូវឱ្យបញ្ចេញមុនពេញដែលត្រូវគណក្រុមប្រឹក្សាក្រុងសម្រេចថា នឹងយកកន្លែងណាមួយជាចុងក្រោយបង្អស់នៅប្រមាណ៦០ថ្ងៃខាងមុខនេះ ។ ប្រជាពលរដ្ឋប្រមាណ៣០០នាក់ មករួមប្រជុំល្ងាចថ្ងៃទី២២មិនានេះនៅ "មជ្ឈមណ្ឌលមនុស្សចាស់"Lowell Senior Center Mars 22nd ។ តាមការ ឬអញ្ជើញរបស់ CBA នឹងប្រមាណ២០០នាក់មករួមប្រជុំគ្នានៅ"សមាគមខ្មែរ"CMAA: Mars 23rd ។ នៅល្ងាចថ្ងៃ២៣មួយថ្ងៃបន្ទាប់មក ។

នៅកន្លែងប្រជុំទាំង២ មានអ្នកឯកទេសខាងគម្រោងរបស់សាលាក្រុងខាងសំណង់ខាងកម្មវិធីសាលារៀនរួមទាំងនាយកវិទ្យាល័យចូលរួមឆ្លើយនឹងសំនួរដ៏ច្រើនរបស់ប្រជាពលរដ្ឋផងក្នុងនោះសមាជិកសហគមន៍ខ្មែរជាច្រើនបានចូលរួម ។ ជម្រើសទាំង៤នោះបានត្រូវបង្ហាញប្រជាពលរដ្ឋនារសៀលទាំង២នោះ:

**១-**ជំរើសទី១,ជួសជុលអាគារវិទ្យាល័យដែលមានសព្វថ្ងៃនេះ

- Field House, Lord Building, Building 1922 & Freshman Academy
- ពង្រីកបន្ថែមនៅ Lord Building ដើម្បីរៀបចំកម្មវិធីបានប្រសើរ
- កំណត់សង់អាគារក្នុងរយពេល៥ឆ្នាំ

**២-**ជម្រើសទី២, ការជួសជុលពង្រីកអាគារដែលមានរួចហើយ

- Lord Building & building 1922
- រុះរើចោល Field House
- ពង្រីកជាអាគារថ្មី Lord Building, Field House &Fresman Academy
- កំណត់សង់អាគារក្នុងរយៈពេល៤ឆ្នាំ

**៣-**ជម្រើសទី៣, ពង្រីកបន្ថែមលើអាគារដែលមានរួចហើយ

- ជួសជុល Lord building & 1922 building
- រុះរើចោល Field House
- ពង្រីកជាថ្មី: Lord building, Freshman Academy & Field House នៅចំណែកផ្លូវ 75 Arcand Dr ។
- កំណត់សង់អាគារក្នុងរយពេល៤ឆ្នាំ

**៤-**ជម្រើសទី៤, សង់អាគារវិទ្យាល័យថ្មីនៅកន្លែង Cawley

- សង់អាគារថ្មីនៅ Cawley Stadium
- សង់ភ្ជាប់នឹងទីលានកីឡាដ្ឋាន: ការពិភក្សាពីទីកីឡាដ្ឋាននោះកំពុងតែធ្វើការពិនិត្យស្រាវជ្រាវ
- កំណត់សង់អាគាររយៈពេល៣ឆ្នាំ






ការសួរយោបល់នឹងពន្យល់ដល់ជនភាគតិចនៃសហគមន៍ពីអ្នកឯកទេសនៃការកែរលំអរវិទ្យាល័យឡូវែល គឺជាឱកាសកម្រដែលកើតស្ទើរ១០០ឆ្នាំទើបមានម្តងនេះឡវាមានសារសំខាន់ជាទីបំផុត សម្រាប់ជួយយឹតយោងយុវជននៃជនជាតិភាគតិចឱ្យអាចទទួលនូវការអប់រំទំនើបមួយបាន ។ ផ្តោតលើបទពិសោធន៍ពីអតីតកាល,មាតាបីតាខ្មែរ គួរចងចាំពីភាពលំបាកលំបិនរបស់ខ្លួនក្នុងការចិញ្ចិមបីបាច់កូនឱ្យចូលរៀននៅសាលប្រសើរនៃសហរដ្ឋអាមេរិក កាលពីពេល ទើបមកដល់ឡូវែលដែលបែរជាលំបាកជាងនៅស្រុកខ្មែរទៅទៀត, លទ្ធផលនៃជោគជ័យរបស់កូនចៅនៅវិទ្យាល័យមិនបាន១០ភាគរយទេ ។ គឺអាយល់ បានថា "ទីតាំងនឹង វិសាលភាព" វិទ្យាល័យដែលកូនរៀន គឺជាផ្នែកមួយនៃបរាជ័យក្នុងការសិក្សារពិអតីតកាល ពីព្រោះយុវជនខ្មែរជាច្រើនបានលង់ក្នុងអបាយមុខនៅតាមផ្លូវទៅសាលារៀននោះឯង ។

សំណង់កែរថ្មីនៅវិទ្យាល័យឡូវែលមានទំនាស់៣ធំៗ ដែលនាំឱ្យបរាជ័យ:

១-សាលានៅកណ្តាលក្រុងពោរពេញទៅដោយហាងដែលទាក់ទាញអារម្មណ៏ឱ្យចេញពីការសិក្សាមានទាំងសុរានឹងគ្រឿងញៀន

២-ទៅដោយជនដែលគ្មានទីលំនៅប្រាកដដែលមកគំរាមកំហែងភាពសុខសាន្តរបស់កូនចៅ

៣-ក្រុងដែលចង្អៀតនឹងកាន់តែចង្អៀតចង្អល់នៅ៥-១០ឆ្នាំខាងមុខទៀត

ទាំងនេះមិនទាន់និយាយពីរចនាសម្ពន្ធចាស់នៃសំណង់ចាស់ដែលមិនស៊ីចង្វាក់គ្នានឹងទំនើបកម្មផង ។ វិទ្យាល័យនៅកន្លែងថ្មីសិស្សមិនថ្លង់នឹងសម្លេងនៃសំណង់,មិនរំខាន៤-៥ឆ្នាំដោយគ្រឿងយន្តធំៗឆ្វាត់ឆ្វែងក្បែរសាលារៀននឹងចុងបញ្ចប់ទទួលបាននូវសាលាថ្មីមួយដែលក្មេងចង់ទៅរៀននៅទីនោះ ។ យានជំនិះមិនចោទជាបញ្ហា! ការរៀន "បន្ទាប់ពីម៉ោងរៀន"ក៏អាចបង្កើតកម្មវិធីនៅទីស្ងប់ស្ងាត់នោះបាន! ។

ការដែលសាលានៅជិតផ្ទះកណ្តាលក្រុងឡូវែលវានឹងចោទបញ្ហាធំមួយ គឺនៅពេលដែលសាលាកំពុងបង្រីកសិស្សនឹងទទួលការរំខាន៤-៥ឆ្នាំ ដោយសារសំណង់កែរថ្មីនោះ -នៅពេលសង់ចប់សំណង់តុលាការក្រុងក៏នឹងចប់ដូចគ្នា វានឹងនាំមនុស្សនឹងរថយន្តរាប់ពាន់ថ្មីមកក្នុងក្រុងឡូវែលជាមួយនឹងសំណង់ថ្មីផ្សេងៗទៀត តើឡូវែលនឹងក្លាយទៅជា"ញូយ៉ក"ថ្មីនៅជនបទដែឬទេ? ក្រុងកកស្ទះ គឺជាការរំខានរបស់អ្នកក្រុងឡូវែល... ពេលនោះឡូវែលនឹងខ្វះដីដែលត្រូវយកសួនច្បារដ៏ល្អៗទៅសង់ជាទីលំនៅ ឬជាហាង... តើអ្នកព្រមទេ?

យើងបានឃើញគម្រោងនោះហើយ, គេបានសួរយោបល់យើងហើយ, យើងក៏មានពេលមិនដល់៦០ថ្ងៃទេ សម្រាប់ស្រែកឱ្យគេឮបំណងរបស់អ្នកសូមលោកអ្នកប្រើសិទ្ធិនេះសម្រាប់ជួយកូនលោកអ្នកនឹងជួយដល់អនាគតនៃសហគមន៍យើងទាំងអស់គ្នា ៕


លោកអភិបាលក្រុងឡូវែលចូលរួមស្តាប់អង្គប្រជុំនៅសមាគមខ្មែរ

## បើកទំព័រថ្មីសម្រាប់ទទួលយោបល់លោកអ្នកអាន

ដើម្បីចូលរួមស្វាគមន៏ឆ្នាំ២០១៧, យើងមានសេចក្តីរីករាយនឹងបើកទំព័រថ្មីម្រាប់ទទួលផ្សាយដោយសេរីនូវគំនិតយោបល់នឹងព័តិមានផ្សេងៗដែលលោកអ្នកអានមានបំណងធ្វើការផ្សព្វផ្សាយជាសាធារណ:នៅរៀងរាល់ពេលដែលយើងទទួលបាននូវអត្ថបទថ្មីពីលោកអ្នក ។

សូមផ្ញើរអត្ថបទ រូបថត ឬ រូបគំនូរ មក info@khmerpost.us សម្រាប់អ្នកដែលចេះប្រើ "អាំងទែណេត" ឬក៏ផ្ញើរមកអស័យដ្ឋាន Khmerpost U.S.A. Editorial

45, Merrimack Street, #218A

Lowell, Lowell MA 01852_USA

សូមសរសេរដោយដៃក្នុងចន្លោះខាងក្រោមនេះរួចកាត់ផ្ញើរមកយើងខ្ញុំ

...............................................................................................................................

...............................................................................................................................

...............................................................................................................................

...............................................................................................................................

...............................................................................................................................

...............................................................................................................................

...............................................................................................................................

...............................................................................................................................

...............................................................................................................................

...............................................................................................................................

...............................................................................................................................

...............................................................................................................................

...............................................................................................................................

...............................................................................................................................

...............................................................................................................................

យើងជឿជាក់ថា គំនិត យោបល់ នឹងព័តិមានពីលោកអ្នកនឹងជួយជាប្រយោជន៏ដល់សហគមន៏ញាតិមិត្ត ក្រុមគ្រួសារជាមិនខាន ។ សូមកុំភ្លេចដាក់ឈ្មោះ ឬដាក់រូបថត សម្រាប់សំគាល់ម្ចាស់អត្ថបទផង ។ **-សូមអរគុណ-**

( អស័យដ្ឋានអ្នកផ្ញើរ )

បិតតែម

Khmerpost U.S.A., Editorial Dep.
45, Merrimack Street, #218A
Lowell, Lowell MA 01852_
USA

បត់ជា២............................................................................................................................................

**អត្ថបទក្នុងសំបុត្រនេះ**

**១-** ជាអត្ថបទ ឬ ព័ត៌មាន សុំឱ្យចុះផ្សាយ
**២-** ជាសំនួរ សុំឱ្យឆ្លើយតាមទំព័រកាសែត
**៣-** ជាសំនួរ សុំឱ្យឆ្លើយតប មិនឱ្យផ្សាយទេ
សំបុត្រនេះអាចបត់ជាពីរ បិទការខាង២ បិតតែមមួយ រួចផ្ញើរមកយើងតាមប៉ុស្តិ៍
- សូមគូសនៅ ១-២ ឬ ៣ ដែលត្រូវនឹងសំបុត្រនេះ


MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលទ្រព្យ

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទ
មកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ

(978) 458-1229
www.marcottelawfirm.com



Element Care

ខ្ញុំគ្មានការព្រួយបារម្ភទៀតទេ។



- ការផ្តល់សេវាធ្មេញដោយឥតគិតថ្លៃ
- ការផ្តល់ជូននូវយានជំនិះដោយឥតគិតថ្លៃ
- ផ្តល់ជូនវ៉ែនតានិងឧបករណ៍ជំនួយការស្តាប់ដោយឥតគិតថ្លៃ
- ការថែទាំតាមផ្ទះនិងផ្តល់ជូននូវអាហារដោយឥតគិតថ្លៃ
- ផ្តល់ជូននូវថ្នាំតាមវេជ្ជបញ្ជាដោយឥតគិតថ្លៃ

នៅជាមួយនឹងកម្មវិធី PACE នៃអង្គការ Element Care, ការថែរក្សានឹងការចំណាយរបស់ខ្ញុំគឺត្រូវបានទទួលខុសត្រូវទាំងស្រុងជំនួសខ្ញុំ។

អ្នកដែលមានសិទ្ធិមាន MassHealth នឹង Medicare គឺមិនត្រូវបង់ថ្លៃទេ។ សូមទាក់ទងមកយើងខ្ញុំបើអ្នកមានតែ Medicare ហើយនឹងការបង់ថ្លៃដោយឯកជន។ គ្រប់សមាជិកទទួលបាននូវការថែទាំសុខភាព, សេវាកម្មពេទ្យឯកទេស-លើកលែងតែសេវាកម្មសង្គ្រោះបន្ទាន់-ដូចជាបានអនុញ្ញាតពីកម្មវិធី PACE, ពុំនោះទេនឹងទទួលខុសត្រូវដោយខ្លួនឯងចំពោះថ្លៃសេវាកម្មមិនបានអនុញ្ញាតជាមុន។
H2222_2016_3K

សូមអញ្ជើញទាក់ទងមកកាន់ទូរសព្ទលេខខាងក្រោមនេះ:
1-877-803-5564
(TTY 711)
ឬក៏តាមរយ:
elementcare.org




**តពីលេខមុន**

ចាប់ពីម៉ោង៨ព្រឹកទៅពលទាហ៊ានមួយក្រុម ទៅនាំ "ចោរ" ពីគុកធំចេញមកធ្វើការក្នុងបន្ទាយក្រៅបន្ទាយ ឬតាមដងផ្លូវតាមតែត្រូវការ -នៅព្រឹកនេះ មាន "ចោរ" ម្នាក់ជាអ្នកស្រោចដំណាំនឹងស្រោចផ្កានឹងម្នាក់ទៀតជាអ្នកកាត់ស្មៅបានត្រូវទាហ៊ានកាន់អាវុធនៅដៃ ដើរតាមពីក្រោយជាប់។ ពាក្យ "ចោរ" សំដៅទៅអ្នកជាប់ទោសក្នុងគុកដែលស្ថិតនៅខាងជើងបន្ទាយ ក្បែរម៉ាស៊ីនទឹកត្រូវបានទាហ៊ាននាំឱ្យចេញមកធ្វើការខាងក្រៅគុក, អ្នកដែលមានទោសស្រាលជិតដល់ពេលចប់ទោស គេមិនដាក់ច្រវ៉ាក់ជើងទេ ច្រវ៉ាក់ជើងនោះសម្រាប់តែអ្នកដែលនៅសល់ទោសច្រើនឆ្នាំ នឹងមានចរិកល្អនៅក្នុងគុក -ព្រឹកមិញ "ចោរ"ម្នាក់កំពុងស្រោចផ្កានៅមុខផ្ទះកុម៉ង់ដង់ស្រាប់តែត្រូវក្ងានដេញហួរ អា "ចោ" នោះរត់ផងស្រែកឱ្យជួយ រីឯទាហ៊ានដែលតាមយាមភ័យក្លាចចោរត់បាត់ ហើយមានទោស ក៏បាញ់ឡើងលើ ស្រែកឱ្យចោលឈប់រត់ ខ្លាចស្លាប់ជាងក្លាចក្ងាន ក៏ឈប់រត់ធ្វើឱ្យក្ងានបានចិត្ត ហួរឡើងរហែកក្តិតខោអស់មួយដុំ, តែស្នូរកាំភ្លើងបានធ្វើឱ្យទាហ៊ាននៅប៉ុស្តិ៍ប្រចាំការរត់មកជួយ តែមិនមានអ្វីកើតឡើងធំដុំទេ -ពួកចោរ ធ្វើការខាងក្រៅ៣-៤ម៉ោងក៏ត្រូវគេនាំត្រឡប់ទៅគុកវិញ ។ ជាទូទៅពួក "ចោរ" ធ្វើការរហូតដល់ថ្ងៃត្រង់បានទទួលបាយប្អូបទាហ៊ានមួយចានម្នាក់យ៉ាងប្លែកមាត់ពីបាយគុកសម្រាកហើយ ធ្វើការបន្តិចទៀតទើបនាំត្រឡប់ទៅគុកវិញ។

ថ្វីត្បិតតែសន្តិសុខមិនធានាក៏ដោយ នារៀងរាល់ថ្ងៃពុធនៅផ្ទះចៅហ្វាយខេត្ត គេមានកម្មវិធីបញ្ចាំងកុនកណ្តាលវាលនៅលើព្រលានវាយ "តេនីស"នឹងលេង"បាស្កិត"។ នៅបន្ទាយប្រពន្ធឬកូនទាហ៊ានចលាចលពពាក់ពពូននៅមុខបន្ទាយរង់ចាំដល់ពេលទៅមើលកុនដែលគេបញ្ចាំងនៅម៉ោង៦ល្ងាច បើមិនមានភ្លៀងទេនោះ។ រថយន្តក្រសួងឃោសនាករខេត្ត គេដឹកសម្ភារៈបំពេរអារម្មណ៍ ដោយយករថយន្ត "វ៉ែន" ដែលមាន "អូប៉ាល័រ" បំពងសម្លេងនៅលើដំបូលមកជាមួយផង មករៀបបញ្ចាំងឱ្យប្រជាជននាំគ្រួសារមើលកំសាន្តជាសាធារណដែរ ។ លោកកុម៉ង់ដង់ ម៉ាំង តែងណែនាំឱ្យភរិយានាំកូនឱ្យទៅមើលកុននៅទីនោះ នៅពេលដែលលោកនឹងលោកស្រីក្នុងសំលៀកបំពាក់ទីក្រុងទៅចូលរួមក្នុពិធីទទួលភ្ញៀវយ៉ាងសាមញ្ញប្រចាំខែ នៅផ្ទះ "រ៉េស៊ីដង់" ដែលនៅក្បែរនោះ ធ្វើឱ្យបរិវេណសាលាខេត្តមានសភាពអ៊ូអរដូចគេធ្វើបុណ្យ។ ចៅពិន នឹងបងៗរបស់ខ្លួន តែងនាំគ្នាទៅកំសាន្តនៅកុន


សម្តេច សីហនុ ទាមទារឱ្យបារាំងចេញពីកម្ពុជាឱ្យបានឆាប់ (១៩៥០)

កណ្តាលវាលនោះណាស់, គេតែងនាំរឿងកំប្លែងមាន "អាសាកឡូ", រឿង "អាធាត់អាស្គម", រឿង "អាចោអាគិញ", រឿង "អាឡាប់យីវ" ឬគំនូរជីវចលនិយាយអប់រំពីបរិដ្ឋាន, អនាម័យ, សុខភាព, បច្ចុប្បន្នភាពក្នុងកម្ពុជានឹងពិភពលោក...។ល។ កុនបញ្ចាំងក្នុងរយពេល១ម៉ោងទៅ១ម៉ោងកន្លះធ្វើឱ្យអ្នកចង់ទៅមើកកុនបញ្ចាំងលើផ្ទាំងសំពត់សធំនោះ ជក់ចិត្តចង់តាមដានទៀត។ ពីកន្លែងមើលកុនទៅ គេអាចឃើញភ្ញៀវនៅក្នុងកន្លែងទទួលភ្ញៀវ "រេស៊ីដង់" ភ្លឺចិញ្ចាញ នៅឈរជុំជជែកគ្នា សើចលេងសប្បាយជប់លៀងភេសជ្ជៈ រវាងមេទ័ពនឹងមន្ត្រីសំខាន់ៗក្នុងខេត្តប្រមាណ៣០-៤០នាក់ តាមរបៀបបារាំងអ្នកបំរើគ្រប់ជ្រុងអ្នកបក់ផ្លិតធំសម្រាប់បន្ទប់ទទួលភ្ញៀវដែលទិដ្ឋភាពជួបជុំគ្នានេះ កើតឡើងទំនងជា១ខែម្តងដែលអ្នកកាសែតចូលចិត្តហៅថាជា "ពិធីជប់លៀងអាណានិគម" ។

គួររំលឹកថា ឆ្នាំ១៩៥២ គឺជាឆ្នាំនៃការផ្ទេរអំណាចពីបារាំងមករដ្ឋបាលខ្មែរកងទ័ពកងប៉ូលិសនឹងកិច្ចការបរទេសនៅតែជាភារៈកិច្ចរបស់បារាំងនៅឡើយ ។ សម្តេចនរោត្តម ស៊ីហនុ ជាព្រះរាជានឹងជាព្រះប្រមុខរដ្ឋមិនមានការទុកចិត្តថា បារាំងនឹងផ្ទេរអំណាចនោះមកថ្វាយព្រះអង្គទេ ម្ល៉ោះហើយទ្រង់ក៏ធ្វើរាជបូជនីយកិច្ច ដើម្បីជម្រុញឱ្យបារាំងចេញបានរឹតតែឆាប់។ នាពេលជាមួយគ្នានោះ ចលនាឯទៀតៗ មានពួកដែលសម្តេច ន. ស៊ីហនុ ហៅថា "ពួកយៀកមិញ" ដែលបង្កើតដោយយួនកុម្មុយនីស្តចលនាឥស្សរៈមានច្រើនក្រុមចលនាក្រុមប្រជាធិបតេយ្យដែលដណ្តើមឥទ្ធិពលគ្នា ដើម្បីយកប្រជាប្រិយភាពនៅពេលបារាំងចេញទិកម្ពុជាទៅអាចនឹងមានការបោះឆ្នោត, ការប្រកួតប្រជែងគ្នានេះ ជួនកាលក៏មានការប៉ះទង្គិចគ្នា រវាងក្រុមនិមួយៗ, ជួនកាលក៏មានទាំងទៅជម្រឹតយកម្ហូបឬមាសពេជ្រពីអ្នកស្រុក ដើម្បីចិញ្ចឹមក្រុមខ្លួន ទៀតផងដែលជាហេតុធ្វើឱ្យមានការប្តឹងផ្តល់ទៅកងអាជ្ញាធរបារាំងដែលមានទ័ពមាំទាំជាងគេ ហើយក៏មានវិន័យនឹងសីលធមិខ្ពស់ ព្រមទាំងមានការប្រើច្បាប់ក៏ខ្លាំងណាស់ដែរ ។

ជាញឹកញយកងប្រតិបត្តិការសិកដែលចេញយប់ព្រលប់តែងចាប់បានជនប្រព្រឹត្តបទល្មើសដែលមានពាក្យប្តឹងផ្តល់ទៅរដ្ឋបាលប៉ូលីស ហើយពាក្យបណ្តឹងនោះបានត្រូវបញ្ជូនមករដ្ឋបាលយោធាដែលមានភារកិច្ចចេញទៅចាប់ខ្លួន ជាពិសេសក្រុមដែលយោធាចាត់ទុកថា ជា "ឧទ្ទាមដ៏គ្រោះថ្នាក់" គឺក្រុមដែលតាំងខ្លួនថាជាកងរំដោះមានកាំភ្លើងតែមានសកម្មភាពជាចោរប្លន់។ បន្ទាយទាហ៊ានបារាំងចំនួន៣ នៅជុំវិញក្រុងរដ្ឋបាលកំពុងស្ថិ ដែលមាន២ដឹកនាំដោយ "កុម៉ង់ដង់" បារាំង ពេលខ្លះជារបងដ៏រឹងមាំសម្រាប់ការពារមិនឱ្យមាឧទ្ទាមចូលមកវាយលុកពេលណាបាននោះទេ, ហើយបន្ទាយទាំង៣នោះ តែងចេញទៅ "ប៉ាទ្រូយ" ឆ្លាស់វេនគ្នាតាមជនបទជាទៀងទាត់ផង។

លោក កុម៉ង់ដង់ ម៉ាំង តែងចេញទៅប្រតិបត្តិការសឹកដោយខ្លួនឯងជាញឹកញយដងដែរ ក៏ប៉ុន្តែដោយសារលោកតែងមានសម្លៀកបំពាក់ "ត្រេអ៊ី" ទៅពិនិត្យកូនទាហ៊ាននៅរាល់ពេលចេញទៅធ្វើ "ប៉ាទ្រូយ" អ្នកណាចង់តាមដានការ ថា "ប៉ាទ្រូយ" នេះមានកុម៉ង់ដង់ចេញទៅដែរ ឬអត់នោះ នឹងមានការលំបាកនឹងស៊ើបដឹងជាប្រាកដ។ នៅសប្តាហ៍នេះ ចៅពិនបានសង្កេតឃើញថា ឪពុកខ្លួនតែងមកពីធ្វើការយឺតពេលខកខានមិនបានចូលរួមតុបាយជាមួយគ្រួសារច្រើនដង, លោកស្រីឃើញប្តីមានកង្វល់ច្រើនដូច្នោះក៏សួរថា :

-ប៉ា!(ហៅជំនួសពាក្យបង) មានប្រុងប្រៀបទៅណា ឬបានជាក្រមកពីធ្វើការច្រើនថ្ងៃហើយនោះ?

-មានសកម្មភាពឥស្សរៈច្រើនកន្លែងបងត្រូវតាមមើលរាល់ថ្ងៃ! លោកស្រីបន្តសួរប្តីទៀតថា:

-ចុះពួកឥស្សរៈនៅក្បែរៗនេះច្រើនមិនដែលមានសកម្មភាពអ្វីទេ ហេតុអ្វីក៏កំរើកនៅពេលនេះ?

-មានពួកថ្មី ទើបមកចូលអុកឡុកមានប្លន់អ្នកស្រុក ហើយមានអ្នកស្រុកគេមកប្តឹង! លោកស្រីហាក់ដូចជាដឹងថា ប្តីមុខជានឹងចេញទៅ "ប៉ាទ្រូយ" ឆាប់ៗខាងមុខនេះជាមិនខានហើយ, មិនមាត់មិនកច្រើន ក៏ធ្វើការបន្តរទៅទៀត ។

មែនរំលង៣-៤ថ្ងៃប៉ុណ្ណោះ នារសៀលមួយនោះ លោក ម៉ាំង ប្រាប់ប្រពន្ធឱ្យរៀបអីវ៉ាន់សម្រាប់ចេញដំណើរល្ងាចនោះតែម្តងមែន ។ លោក ម៉ាំង មិនដែលឱ្យដំណឹងពីដំណើរទៅប្រតិបត្តិការណ៍សឹកទៅប្រពន្ធឱ្យបានយូរជាមុនទេ តែលោកស្រីបានរៀបខោអាវ "ត្រេអ៊ី" មានមួកមានស្បែកជើង មានខ្សែរក្រវ៉ាត់ "សាំងទូរ៉ុង" មានសំបកត្រពាំងមាន "សាកាដូ"... រួចជាស្រេចបន្ថែមពីនេះ លោកស្រីបានរៀបកំប៉ុងសម្រាប់ដាំកាហ្វេនឹងគ្រឿងគ្រៅសម្រាប់ឆុងរួចជាស្រេចមិនឱ្យយឺតពេលបានឡើយ ។ លោក កុម៉ង់ដង់ ម៉ាំង មិនពិសារស្រាទេ មិនជក់បារីទេ តែកាហ្វេវិញ អត់មិនបានទេ, ដល់ម៉ោងចេញដំណើរ លោកយកទាហ៊ាន "អ័រដូណង់" ម្នាក់ឈ្មោះ សាយ ជាមនុស្សដែលធ្លាប់បំរើត្រូវចិត្តមកឱ្យស្ពាយ "សាកកាដូ" ដែលក្នុងនោះមានគ្រឿងឆុងកាហ្វេទៅជាមួយ មិនដែលខានទេ។ មុននឹងចេញពីផ្ទះលោក ម៉ាំង តែងយកកន្សែងយ័ន្តធ្វើពីក្រណាត់សពីរផ្ទាំងដែលមានគំនូរបាតដៃនឹងបាតជើងទាំងសងខាងរបស់ម្តាយនឹងឪពុករបស់លោកបត់ដាក់ក្នុងមួកពាក់លើក្បាលជាការដឹងគុណម្តាយឪពុក តាមជំនឿខ្មែររបស់លោកមិនមានដោះមួករហូតដល់ត្រឡប់មកដល់ផ្ទះវិញ។

ពេលចេញដំណើរមកដល់លោកកុំម៉ង់ដង់មានតែកាំភ្លើងខ្លីនៅក្នុងស្រោមស្បែកមួយតែប៉ុណ្ណោះ, លោកចង្អុលលើផែនទីទាហ៊ាននូវទីកន្លែងដែលត្រូវទៅមានអ្នកកាន់វិទ្យុនៅក្បែររួចរាល់ហើយក៏បញ្ជាឱ្យចេញដំណើរទៅតាមមុខបន្ទាយបត់ទៅ **តទៅលេខក្រោយ**

# ផ្សព្វផ្សាយទៅដល់អ្នកអានក្នុងសហគមន៍ខ្មែរច្រើនជាងគេបង្អស់នៅសហរដ្ឋអាមេរិក

កាសែតខ្មែរផុស ស.រ.អា គឺជាកាសែតភាសារខ្មែរ- អង់គ្លេសពណ៌ធម្មជាតិ មានចំនួន៣២ទំព័រដែលបោះពុម្ពផ្សាយជារៀងរាល់ពីរសប្តាហ៍ម្តងចំនួន៥,០០០ច្បាប់ និងធ្វើការបែងចែកដោយមិនគិតថ្លៃទៅកាន់៦០កន្លែងក្នុងតំបន់ឡូវេល។ រៀបចំពេលវេលាផ្សព្វផ្សាយពាណិជ្ជកម្មសម្រាប់ឆ្នាំ២០១៧ របស់លោកអ្នកជាមួយយើងខ្ញុំថ្ងៃនេះ!

**កាលបរិច្ឆេទនៃការបោះពុម្ពផ្សាយ**

- ថ្ងៃទី ១០ និង ២៤ ខែមិនា
- ថ្ងៃទី ៧ និង ២១ ខែមេសា
- ថ្ងៃទី ៥ និង ១៩ ខែឧសភា
- ថ្ងៃទី ៩ និង ២៣ ខែមិថុនា
- ថ្ងៃទី ៧ និង ២១ ខែកក្កដា
- ថ្ងៃទី ៤ និង ៩ ខែសីហា
- ថ្ងៃទី ៨ និង ២២ ខែតុលា
- ថ្ងៃទី ៦ និង ២០ ខែកញ្ញា
- ថ្ងៃទី ៣ និង ១៧ ខែវិច្ឆិការ
- ថ្ងៃទី ៨ និង ២២ ខែធ្នូ

* រាល់ព័ត៌មាននៃការផ្សព្វផ្សាយទាំងអស់ ត្រូវផ្ញើមកកាន់យើងខ្ញុំឲ្យបាន៣ថ្ងៃមុនការបោះផ្សាយ។

## ទំនាក់ទំនងមក ពិន សុបិន សម្រាប់ឱកាសនៃការផ្សព្វផ្សាយពាណិជ្ជកម្មរបស់លោកអ្នក

អ៊ីម៉េល:sobenpin@khmerpost.us

978-677-7163

អសយដ្ឋានការិយាល័យកាសែតខ្មែរផុសស.រ.អា

KhmerPost USA, 45Merrimack St. Suite 218A Lowell, MA 01852
ម៉ោងបំរើការងារ: ថ្ងៃច័ន្ទ - សុក្រ ចាប់ពី 9:00 ព្រឹក ដល់ម៉ោង ៤:00 ល្ងាច

Online at: http://khmerpost.us

**សូមគត់សម្គាល់ថ្ងៃប្រារព្វខួបទី១០ ឆ្នាំ នៃសារព័ត៌មានខ្មែរផុសស.រ.អា**

**ថ្ងៃសុក្រ ទី១៩ ខែឧសភា ឆ្នាំ២០១៧**

នៅសណ្ឋាគារយូម៉ាស ឡូវេល អាយអ៊ិនអ៊ិន អែន ខនហ្វឺរេន

(អតីតសណ្ឋាគារ ឌិបបូលទ្រី)